ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២៦ លេខ៣៩ ត្រីមាសទី០២ ឆ្នាំ២០២៦

# រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរ ប្រកាស

# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


២៣-៥-២០២៦ -ព្រះរាជក្រម នស/រកម/០៥២៦/០០៨ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពីកាតព្វកិច្ចយោធា ៤៦៤៣


### ២~ព្រះរាជក្រឹត្យ


២១-៥-២០២៦ -ព្រះរាជក្រឹត្យ នស/រកត/០៥២៦/៥៤២ ស្តីពី ការតែងតាំង និងផ្តល់ឋានៈជាទីប្រឹក្សា ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ ព្រឹទ្ធសភា នីតិកាលទី៥ ដោយពុំទទួលប្រាក់បំណាច់មុខងារ ៤៦៥០

២១-៥-២០២៦ -ព្រះរាជក្រឹត្យ នស/រកត/០៥២៦/៥៤៣ ស្តីពី ការផ្តល់គោរមងារ លោកស្រី **គ្រី ឌួចឆួន** ជា ឧកញ៉ា ៤៦៥១

២១-៥-២០២៦ -ព្រះរាជក្រឹត្យ នស/រកត/០៥២៦/៥៤៤ ស្តីពី ការផ្តល់គោរមងារ លោក **ឡាច ង៉ៀហាច** ជា ឧកញ៉ា ៤៦៥២

២១-៥-២០២៦ -ព្រះរាជក្រឹត្យ នស/រកត/០៥២៦/៥៤៥ ស្តីពី ការផ្តល់គោរមងារ លោកស្រី **ឡាច ង៉ៀជីន** ជា ឧកញ៉ា ៤៦៥៣

២១-៥-២០២៦ -ព្រះរាជក្រឹត្យ នស/រកត/០៥២៦/៥៤៦ ស្តីពី ការតែងតាំង និងផ្តល់ឋានៈជាទីប្រឹក្សាគណៈ-កម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ២រូប និងតែងតាំងឯកឧត្តម **សួរ សុជាតិ** ជាទីប្រឹក្សាគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ៤៦៥៤

២១-៥-២០២៦ -ព្រះរាជក្រឹត្យ នស/រកត/០៥២៦/៥៤៧ ស្តីពី ការតែងតាំងមុខតំណែងឯកឧត្តម **ឡុង សុខា** ជាអនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី និងតែងតាំងមន្ត្រីរាជការ នៃទីស្តីការគណៈរដ្ឋមន្ត្រី ២រូប ៤៦៥៦

២១-៥-២០២៦ -ព្រះរាជក្រឹត្យ នស/រកត/០៥២៦/៥៤៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសសហមេត្រី ថ្នាក់ មហាសេនា ចំពោះ លោក Ben O’Reilly ទីប្រឹក្សាអមស្ថានទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា ៤៦៥៨

២១-៥-២០២៦ -ព្រះរាជក្រឹត្យ នស/រកត/០៥២៦/៥៤៩ ស្តីពី ការលើកលែងទោសឱ្យទណ្ឌិតឈ្មោះ **ស៊ូ អេរ៉ាហ្វាត់** ភេទប្រុស ដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់រយៈពេល ៧ឆ្នាំ តាមអំណាចសាលដីកាព្រហ្មទណ្ឌស្ថាពរលេខ ៤០ ក្រV "រ" ៤៦៥៩

២១-៥-២០២៦ -ព្រះរាជក្រឹត្យ នស/រកត/០៥២៦/៥៥០ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈចំពោះនាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទដែលបានទទួលមរណភាព ៥រូប ៤៦៦០

២២-៥-២០២៦ -ព្រះរាជក្រឹត្យ នស/រកត/០៥២៦/៥៥៧ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម **ណាម ពិសិដ្ឋ** ជាទីប្រឹក្សាអមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៤៦៦២

២២-៥-២០២៦ -ព្រះរាជក្រឹត្យ នស/រកត/០៥២៦/៥៥៨ ស្តីពី ការតាំងស៊ប់ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដល់មន្ត្រីរាជការ ៣រូប ៤៦៦៣

២២-៥-២០២៦ -ព្រះរាជក្រឹត្យ នស/រកត/០៥២៦/៥៥៩ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី ដល់នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ២រូប ៤៦៦៥

២២-៥-២០២៦ -ព្រះរាជក្រឹត្យ នស/រកត/០៥២៦/៥៦០ ស្តីពី ការលើកលែងទោសឱ្យទណ្ឌិតឈ្មោះ TANGUY EDDIE J TALLER ភេទប្រុស ដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់រយៈពេល អស់មួយជីវិត តាមអំណាចសាលក្រមព្រហ្មទណ្ឌស្ថាពរលេខ ០៦ "III" ៤៦៦៦


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


២៧-៤-២០២៦ -អនុក្រឹត្យលេខ ៦៩ អនក្រ.បក ស្តីពី លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ៤៦៦៧

២៤-៤-២០២៦ -អនុក្រឹត្យលេខ ៣៧៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤៦៨០

២៤-៤-២០២៦ -អនុក្រឹត្យលេខ ៣៧៨ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៤៦៨៥

២៤-៤-២០២៦ -អនុក្រឹត្យលេខ ៣៧៩ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤៦៨៧

២៤-៤-២០២៦ -អនុក្រឹត្យលេខ ៣៨០ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៤៦៨៩

២៤-៤-២០២៦ -អនុក្រឹត្យលេខ ៣៨១ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៤៦៩៣

២៤-៤-២០២៦ -អនុក្រឹត្យលេខ ៣៨២ អនក្រ.តត ស្តីពី ការកែសម្រួលសមាសភាពក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម អាណត្តិទី២ ៤៦៩៤

២៤-៤-២០២៦ -អនុក្រឹត្យលេខ ៣៨៣ អនក្រ.តត ស្តីពី ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិមន្ត្រីរាជការ ៤៦៩៦

២៧-៤-២០២៦ -អនុក្រឹត្យលេខ ៣៨៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤៧១៥

២៧-៤-២០២៦ -អនុក្រឹត្យលេខ ៣៨៥ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤៧២២

២៧-៤-២០២៦ -អនុក្រឹត្យលេខ ៣៨៦ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤៧៣១


### ២~សេចក្តីសម្រេច


២៩-៤-២០២៦ -សេចក្តីសម្រេចលេខ ៥២ សសរ ស្តីពី ការចាត់តាំងបន្ថែមសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តឧត្តរមានជ័យ ៤៧៤៤


### ៣~សារាចរ


២០-៤-២០២៦ -សារាចរលេខ ០៥ សរ ស្តីពី ការរៀបចំខួបអនុស្សាវរីយ៍លើកទី១៤០ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៦ ៤៧៤៦


## III~ការងារបណ្តាក្រសួង

### ១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


១៧-២-២០២៦ -ប្រកាសលេខ ១៤៧ សហវ.ប្រក.អរតន ស្តីពី ការតែងតាំងភ្នាក់ងារបើកផ្តល់ និងភ្នាក់ងារបើកផ្តល់ជំនួសរបស់អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ៤៧៤៨

១២-៣-២០២៦ -ប្រកាសអន្តរក្រសួងលេខ ១៨២ សហវ.ប្រក.អរតន ស្តីពី ការបង្កើតរជ្ជទេយ្យចំណូលនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៤៧៥១

២០-៤-២០២៦ -ប្រកាសអន្តរក្រសួងលេខ ២៣៦ សហវ.ប្រក.អរតន ស្តីពី ការបង្កើតរជ្ជទេយ្យចំណូលនៅក្រសួងទេសចរណ៍ ៤៧៥៤

២៨-៤-២០២៦ -ប្រកាសអន្តរក្រសួងលេខ ៣៤៤ សហវ.ប្រក.អទច ស្តីពី ការបែងចែកចំណូលពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ៤៧៥៧

១៨-៥-២០២៦ -ប្រកាសអន្តរក្រសួងលេខ ៣៧៩ សហវ.ប្រក.អដជ ស្តីពី ការកែសម្រួលគណៈកម្មាធិការ សម្រាប់គ្រប់គ្រងកិច្ចព្រមព្រៀងសម្បទានគម្រោង ផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ ៤៧៦១
១៣-៤-២០២៦ -សេចក្តីសម្រេចលេខ ០៣៤ សហវ.សសវ.អលសា ស្តីពី ការបង្កើតក្រុមលទ្ធកម្មរបស់ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ៤៧៦៥

## ២~ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

២៨-១-២០២៦ -ប្រកាសលេខ ០៥៤ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ធេនថេក ខមភើហ្សាយ (ខេមបូឌា) ឯ.ក បង្កើតរោងចក្រផលិតគ្រឿងបន្លាស់ទោចក្រយាន (កង់) ៤៧៦៨

# ព្រះរាជក្រម

នស/រកម/០៥២៦/ ០០៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីកាតព្វកិច្ចយោធា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៦ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៦ នាសម័យប្រជុំព្រឹទ្ធសភាលើកទី៥ នីតិកាលទី៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# ភាតព្វកិច្ចយោធា



## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ច្បាប់នេះកំណត់អំពីរបៀបនៃការអនុវត្តកាតព្វកិច្ចយោធា ដើម្បីរួមចំណែកកសាងប្រទេសជាតិនិងការពារមាតុភូមិ ដែលជាកាតព្វកិច្ចចាំបាច់និងជាកិត្តិយសដ៏ឧត្តុង្គឧត្តមរបស់ប្រជាពលរដ្ឋខ្មែរ និងជាមូលដ្ឋានគ្រឹះនៃប្រភពកសាងកម្លាំងសម្រាប់វិស័យការពារជាតិនិងការអភិវឌ្ឍកាយសម្បទា ព្រមទាំងការបណ្ដុះស្មារតីស្នេហាជាតិ ការអប់រំផ្នត់គំនិត និងវិន័យដែលជាតម្រូវការរបស់ប្រទេសជាតិ។

**មាត្រា២ .-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះប្រជាពលរដ្ឋខ្មែរគ្រប់រូបមានអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ដល់ ២៥ (ម្ភៃប្រាំ) ឆ្នាំ ដែលត្រូវបំពេញកាតព្វកិច្ចយោធា តាមការកំណត់នៃច្បាប់នេះ។

ការបំពេញកាតព្វកិច្ចយោធារបស់ប្រជាពលរដ្ឋខ្មែរជាស្ត្រី ត្រូវផ្អែកតាមគោលការណ៍ស្ម័គ្រចិត្ត។

ប្រជាពលរដ្ឋខ្មែរដែលមានសញ្ជាតិច្រើន ហើយដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញកាតព្វកិច្ចយោធាក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រជាពលរដ្ឋខ្មែរដែលត្រូវចូលបំពេញកាតព្វកិច្ចយោធា ត្រូវមានលក្ខណសម្បត្តិដូចយោធិនអាជីព ដូចមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ។

## ជំពូកទី២
## រយៈពេលនៃការចូលបំពេញកាតព្វកិច្ចយោធា និងលក្ខន្តិកៈដោយឡែកនៃយោធិនបម្រុង

**មាត្រា៣ .-**

ការបំពេញកាតព្វកិច្ចយោធា មានរយៈពេលកំណត់ ២៤ (ម្ភៃបួន) ខែ គិតពីថ្ងៃចូលបំពេញកាតព្វកិច្ច។ ក្នុងករណីចាំបាច់ កាតព្វកិច្ចយោធាអាចបន្តបានដោយមិនឱ្យលើសពី ៦ (ប្រាំមួយ) ខែ តាមការកំណត់របស់រាជរដ្ឋាភិបាល។

ចំនួនប្រជាពលរដ្ឋនិងលក្ខខណ្ឌទាំងឡាយក្នុងការចូលបំពេញកាតព្វកិច្ចយោធា សម្រាប់វគ្គនីមួយៗ រៀងរាល់ឆ្នាំ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ។

**មាត្រា៤ .-**

យោធិនដែលបានបញ្ចប់កាតព្វកិច្ចយោធាហើយ ត្រូវអនុញ្ញាតឱ្យទៅកាន់ជីវភាពស៊ីវិលវិញ ប៉ុន្តែត្រូវស្ថិតក្នុងបញ្ជីយោធិនបម្រុង រហូតដល់អាយុ ៤៥ (សែសិបប្រាំ) ឆ្នាំ។ យោធិននេះក៏អាចស្ថិតនៅក្នុងអាជីពយោធាបន្តទៅទៀតបាន ទៅតាមតម្រូវការរបស់ក្រសួងការពារជាតិនិងដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត។

ក្នុងស្ថានភាពជាយោធិនបម្រុងនេះ សាមីជនត្រូវមកបំពេញភារកិច្ចក្នុងកងយោធពលខេមរភូមិន្ទ តាមការអញ្ជើញគ្រប់ពេលវេលា តាមការចាំបាច់របស់ប្រទេសជាតិ តាមគ្រប់រូបភាព និងតាមកាលៈទេសៈតម្រូវ តាមការកំណត់របស់រាជរដ្ឋាភិបាល។

**មាត្រា៥ .-**

លក្ខន្តិកៈដោយឡែកនៃយោធិនបម្រុង ត្រូវកំណត់ដោយព្រះរាជក្រឹត្យ។



ងង

## ជំពូកទី៣
## ការចុះបញ្ជី ការអញ្ជើញ ការពន្យារពេល និងការអនុញ្ញាតឱ្យរួចផុតពីកាតព្វកិច្ចយោធា

**មាត្រា៦ ._**

ប្រជាពលរដ្ឋខ្មែរគ្រប់រូបដែលដល់អាយុត្រូវបំពេញកាតព្វកិច្ចយោធា ត្រូវអញ្ជើញទៅចុះឈ្មោះក្នុងបញ្ជីជំរឿនកាតព្វកិច្ចយោធា។ ការធ្វើជំរឿន ត្រូវអនុវត្តចំពោះប្រជាពលរដ្ឋខ្មែរគ្រប់រូបដែលមានអាយុចាប់ពី ១៧ (ដប់ប្រាំពីរ) ឆ្នាំឡើងទៅ។

ប្រជាពលរដ្ឋខ្មែរដែលមានឈ្មោះក្នុងបញ្ជីតម្រូវឱ្យចូលបំពេញកាតព្វកិច្ចយោធា ត្រូវទទួលបាននូវការជូនដំណឹងអំពីកាលបរិច្ឆេទនិងទីកន្លែងនៃការចុះឈ្មោះចូលបំពេញកាតព្វកិច្ចយោធា។

លក្ខខណ្ឌនិងបែបបទនៃការធ្វើជំរឿន ការជ្រើសរើស ការអញ្ជើញ និងការអនុវត្តកាតព្វកិច្ចយោធា ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៧ ._**

ប្រជាពលរដ្ឋដែលត្រូវបានជ្រើសរើសឱ្យចូលបំពេញកាតព្វកិច្ចយោធា អាចដាក់ពាក្យសុំពន្យារពេល ១ (មួយ) ឆ្នាំម្តងៗ។

លក្ខខណ្ឌនិងបែបបទនៃការពន្យារពេល ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៨ ._**

ការអនុញ្ញាតឱ្យរួចផុតពីកាតព្វកិច្ចយោធា ត្រូវអនុវត្តចំពោះ៖

- ព្រះសង្ឃ បព្វជិតនៃសាសនាផ្សេងៗ ដែលមានការទទួលស្គាល់ពីក្រសួងធម្មការនិងសាសនា
- ប្រជាពលរដ្ឋដែលមានសមត្ថភាពឬទេពកោសល្យពិសេស ក្នុងវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ដែលមានការបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច
- អ្នកឯកទេសជំនាញដែលបានចុះកិច្ចសហប្រតិបត្តិការបំពេញបេសកកម្មស្រាវជ្រាវឬអនុវត្តផ្ទាល់នូវកិច្ចការដែលជាប្រយោជន៍ផ្នែកសាធារណៈនៃកងយោធពលខេមរភូមិន្ទ ដែលមានរយៈពេលកំណត់ស្មើនឹងរយៈពេលបំពេញកាតព្វកិច្ចយោធាដូចមានកំណត់ក្នុងច្បាប់នេះ
- ប្រជាពលរដ្ឋដែលបានបញ្ចប់សេវាជាយោធិនជាប់កិច្ចសន្យាស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ប្រជាពលរដ្ឋដែលមានកាយសម្បទាមិនគ្រប់គ្រាន់តាមការតម្រូវ ដោយមានការត្រួតពិនិត្យជាក់ស្តែងពីគណៈកម្មការសុខាភិបាល។

## ជំពូកទី៤
## កាតព្វកិច្ចនិងអត្ថប្រយោជន៍នៃការបំពេញកាតព្វកិច្ចយោធា

**មាត្រា៩ ._**

ក្នុងរយៈពេលនៃការបំពេញកាតព្វកិច្ចយោធា យោធិនគ្រប់រូបត្រូវទទួលបានប្រាក់ឧបត្ថម្ភនិងគោលរបបផ្សេងៗ ដែលត្រូវកំណត់ដោយអនុក្រឹត្យ។

យោធិនមានជំងឺ ឬរងរបួស ឬគ្រោះថ្នាក់ផ្សេងៗ ត្រូវទទួលបានការសង្គ្រោះ ការព្យាបាល និងការថែទាំពីក្រសួងការពារជាតិ។ ក្នុងករណីយោធិនពលី មរណៈ ឬពិការ ដោយសារបុព្វហេតុជាតិមាតុភូមិពេលបំពេញបេសកកម្មក្នុងអំឡុងពេលនៃការបំពេញកាតព្វកិច្ចយោធា យោធិនត្រូវទទួលបានគោលរបបផ្សេងៗ ដែលត្រូវកំណត់ដោយអនុក្រឹត្យ។

យោធិនដែលបានបង្កើតស្នាដៃល្អក្នុងពេលបំពេញកាតព្វកិច្ចយោធា ត្រូវបានលើកទឹកចិត្តនិងសរសើរដូចយោធិនអាជីព។

**មាត្រា១០ .-**

ក្នុងរយៈពេលនៃការបំពេញកាតព្វកិច្ចយោធា យោធិនគ្រប់រូបត្រូវគោរពតាមបទវិន័យទូទៅសម្រាប់កងយោធពលខេមរភូមិន្ទ ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា១១ .-**

យោធិនដែលបានបញ្ចប់កាតព្វកិច្ចយោធា ត្រូវទទួលបានការលើកទឹកចិត្ត ដែលត្រូវកំណត់ដោយអនុក្រឹត្យ។

ស្ថាប័នរដ្ឋ សហគ្រាសសាធារណៈឬឯកជននានា និងអង្គការសង្គមស៊ីវិល ត្រូវទទួលឱ្យប្រជាពលរដ្ឋដែលបានបញ្ចប់កាតព្វកិច្ចយោធានោះ ចូលបម្រើការងារវិញក្នុងក្របខ័ណ្ឌដើម ដោយរក្សាមុខតំណែងដូចមុនពេលទៅបំពេញកាតព្វកិច្ចយោធា ហើយផ្តល់អាទិភាពក្នុងការពិចារណាដំឡើងមុខតំណែង ឬថ្នាក់ ឬឋានន្តរសក្តិ។ រយៈពេលនៃការបំពេញកាតព្វកិច្ចយោធា ត្រូវបានរាប់បញ្ចូលក្នុងអតីតភាពសម្រាប់ការដំឡើងថ្នាក់ ឬឋានន្តរសក្តិ ឬការចូលនិវត្តន៍របស់សាមីជនផងដែរ។

គ្រឹះស្ថានសាធារណៈឬឯកជននានា ត្រូវទទួលឱ្យសិស្ស និស្សិតដែលបានបញ្ចប់កាតព្វកិច្ចយោធានោះបន្តការសិក្សាវិញ ដោយរក្សាលទ្ធផលនៃការសិក្សាកន្លងមករបស់សាមីជន។

បែបបទនិងនីតិវិធីក្នុងការទទួលយកប្រជាពលរដ្ឋដែលបញ្ចប់កាតព្វកិច្ចយោធាឱ្យចូលបម្រើការងារ ឬបន្តការសិក្សាវិញ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៥
## សមត្ថកិច្ចតុលាការ

**មាត្រា១២ .-**

បទល្មើសព្រហ្មទណ្ឌដែលមានចែងក្នុងច្បាប់នេះ ត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់តុលាការយោធា។

## ជំពូកទី៦
## ទោសប្បញ្ញត្តិ

**មាត្រា១៣ .-**

ប្រជាពលរដ្ឋគ្រប់រូប ដែលត្រូវបានអញ្ជើញឱ្យចូលបំពេញកាតព្វកិច្ចយោធា ហើយមិនបានមកបង្ហាញខ្លួនតាមការអញ្ជើញក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតពីថ្ងៃដែលសាមីខ្លួនបានទទួលដំណឹង ត្រូវចាត់ទុកជាជនដែលគេចវេះពីកាតព្វកិច្ចយោធា លើកលែងតែមានមូលហេតុត្រឹមត្រូវដែលជននោះពុំអាចមកបង្ហាញខ្លួនបានតាមការកំណត់។

ជនណាដែលគេចវេះពីកាតព្វកិច្ចយោធា ត្រូវផ្តន្ទាទោស ដូចខាងក្រោម៖

- ដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល ប្រសិនបើអំពើនេះ ត្រូវបានប្រព្រឹត្តក្នុងកាលៈទេសៈដែលប្រទេសមានសន្តិភាព
- ដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ប្រសិនបើអំពើនេះ ត្រូវបានប្រព្រឹត្តក្នុងកាលៈទេសៈដែលប្រទេសមានសង្គ្រាមឬរងការឈ្លានពានពីកម្លាំងបរទេស។

បញ្ញត្តិនៃកថាខណ្ឌទី២ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះជនណាដែលគេចវេះក្នុងអំឡុងពេលនៃការអនុវត្តកាតព្វកិច្ចយោធាដែលបានកំណត់ក្នុងច្បាប់នេះ។

ក្នុងករណីជនល្មើសទទួលកំហុសរបស់ខ្លួន ហើយសុខចិត្តចូលមកបំពេញកាតព្វកិច្ចយោធាវិញនៅមុនពេលដែលមានសេចក្ដីសម្រេចជាស្ថាពរពីតុលាការ ជននោះត្រូវទទួលបានការអនុគ្រោះពីការផ្ដន្ទាទោស ប៉ុន្តែត្រូវបញ្ជូនជននោះទៅអនុវត្តទណ្ឌកម្មវិន័យ។ បែបបទនិងនីតិវិធីនៃការអនុវត្តទណ្ឌកម្មវិន័យ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ។

**មាត្រា១៤ .-**

ការញុះញង់ឱ្យគេចវេះពីការបំពេញកាតព្វកិច្ចយោធា ត្រូវផ្ដន្ទាទោសដូចគ្នានឹងបទល្មើសគេចវេះពីកាតព្វកិច្ចយោធា ដូចមានចែងក្នុងមាត្រា១៣ នៃច្បាប់នេះ។

អ្នកផ្ដើមគំនិតឬសមគំនិតនៃបទល្មើសដូចមានចែងក្នុងច្បាប់នេះ ត្រូវផ្ដន្ទាទោសដូចគ្នានឹងចារីដែរ។

**មាត្រា១៥ .-**

ជនណាដែលឆ្លៀតយកឋានៈនិងតួនាទី ដើម្បីរាំងស្ទះមិនឱ្យប្រជាពលរដ្ឋចូលបំពេញកាតព្វកិច្ចយោធា ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល។

**មាត្រា១៦ .-**

ចំពោះជនណាដែលប្រព្រឹត្តបទល្មើសដែលមានចែងក្នុងមាត្រា១៣ មាត្រា១៤ និងមាត្រា១៥ នៃច្បាប់នេះ តុលាការអាចប្រកាសទោសបន្ថែមមួយឬច្រើន ដូចមានចែងក្នុងមាត្រា៥៣ (ប្រភេទនៃទោសបន្ថែម) នៃក្រមព្រហ្មទណ្ឌ។

បែបបទនិងនីតិវិធីសម្រាប់ការអនុវត្តទោសបន្ថែមទាំងនេះ ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ។

**មាត្រា១៧ .-**

ការអនុវត្តទោសប្បញ្ញត្តិនៃជំពូកទី៦ នៃច្បាប់នេះ មិនរារាំងដល់ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត ក្នុងករណីដែលអំពើដែលកំណត់ថាជាបទល្មើសដែលមានចែងក្នុងច្បាប់នេះ ជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌផ្សេងទៀត។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**មាត្រា១៨ .-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធនឹងការអនុវត្តច្បាប់ស្ដីពីកាតព្វកិច្ចយោធា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣០ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៦ ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា១៩ .-**

ច្បាប់ស្ដីពីកាតព្វកិច្ចយោធាដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣០ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៦ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២០ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សៅរ៍ ១២ កើត ខែ ផល្គុន ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០២៦

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាស់បន្ទាប់**
**ប្រមុខរដ្ឋស្តីទី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ពរល. ២៦០៥. ៥៨២

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងការពារជាតិ**

នាយឧត្តមសេនីយ៍ **ទៀ សីហា**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**រដ្ឋមន្ត្រីស្តីទី**

**បណ្ឌិតសភាចារ្យ ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០៥២៦/៥៤៥

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផល នៃការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ ព្រឹទ្ធសភា នាសម័យប្រជុំលើកដំបូងព្រឹទ្ធសភា នីតិកាលទី៥ នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៤
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំង និងផ្តល់ឋានៈជាទីប្រឹក្សា ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ ព្រឹទ្ធសភា នីតិកាលទី៥ ដោយពុំទទួលប្រាក់បំណាច់មុខងារៈ

១- ឯកឧត្តម អ៊ុក សុទ្ធសេន មានឋានៈស្មើ រដ្ឋលេខាធិការ
២- ឯកឧត្តម ឡ ហុង មានឋានៈស្មើ អនុរដ្ឋលេខាធិការ
៣- ឯកឧត្តម សុក ប៊ុនធេង មានឋានៈស្មើ អនុរដ្ឋលេខាធិការ
៤- ឯកឧត្តម ស វ៉ាន់ហ៊ាង មានឋានៈស្មើ អនុរដ្ឋលេខាធិការ។

**មាត្រា២ :** តែងតាំងលោកជំទាវ យូ ម៉ូលីន ជាទីប្រឹក្សា ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ ព្រឹទ្ធសភា នីតិកាលទី៥ ដោយពុំទទួលប្រាក់បំណាច់មុខងារ។

**មាត្រា៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៦
**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ចរស. ២៦០៥. ៥៤៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០៥២៦/៥៤៣

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

ផ្តល់គោរមងារៈ

លោកស្រី **គ្រី ខួចឆួន**

ជា

**ឧកញ៉ា**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០២៦

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ចរស. ២៦០៥.៥៥០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០៥២៦/៥៤៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

ផ្តល់គោរមងារៈ

លោក **ឡាច ជៀហាច**

ជា

**ឧកញ៉ា**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៦

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ពអរ. ២៦០៥. ៥៥១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០៥២៦/៥៤៥

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

យោងតាមសេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

ផ្ដល់គោរមងារៈ

លោកស្រី **ឡាច ជៀជីន**

ជា

**ឧកញ៉ា**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៤១ ខែឧសភា ឆ្នាំ២០២៦

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្ដីទី**

ពរស. ២៦០៥. ៥៥២

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី
រដ្ឋលេខាធិការប្រចាំការ

បណ្ឌិតសភាចារ្យ ហ៊ីង ថុរ៉ាក់ស៊ី

# ព្រះរាជក្រឹត្យ

នស/រកត/០៥២៦/៥៤៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៥/០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២៣១១ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងនិងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៣៧ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីគោលការណ៍សម្រាប់ការតែងតាំងទីប្រឹក្សា និងជំនួយការនៅក្នុងអង្គការនីតិប្រតិបត្តិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១.-** តែងតាំង និងផ្តល់ឋានៈជាទីប្រឹក្សាគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ២រូប៖

១-ឯកឧត្តម **ឃុន សុខា** មានឋានៈស្មើ រដ្ឋលេខាធិការ

២-ឯកឧត្តម **គឹម វឌ្ឍនា** មានឋានៈស្មើ រដ្ឋលេខាធិការ។

**មាត្រា២** : តែងតាំងឯកឧត្តម **សូរ សុជាតិ** ជាទីប្រឹក្សាគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។

**មាត្រា៣** : សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ២០២៦

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

ពរសៈ ២៦០៥. ៥៥៣

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់សុី**

# ព្រះរាជក្រឹត្យ

នស/រកត/០៥២៦/៥៤៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងមុខតំណែងឯកឧត្តម **ឡុង សុខា** ជាអនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា២** : តែងតាំងមន្ត្រីរាជការ នៃទីស្តីការគណៈរដ្ឋមន្ត្រី ២រូបៈ

| | |
|---|---|
| ១- ឯកឧត្តម **សុទ្ធ ធី** | អត្តលេខ ១៦៧០៣០០០២២ ឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ១ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជាអគ្គនាយក នៃអគ្គនាយកដ្ឋានបរិវត្តកម្មឌីជីថល |
| ២- ឯកឧត្តម **លី សុធីរ័ត្ន** | អត្តលេខ ១៧៥០៨០០៤៣៨ ឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ៣ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជាអគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការសង្គមកិច្ចនិងវប្បធម៌។ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៣** : សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មករា ឆ្នាំ២០២៦

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

នស. ២៦០៥. ៥៥៥

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

**បណ្ឌិតសភាចារ្យ ហ៊ីង ថូរ៉ាក់សុី**

# ព្រះរាជក្រឹត្យ

**យើង**

នស/រកត/០៥២៦/៥៤៥

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ប្រោសព្រះរាជទាន**

នូវ

គ្រឿងឥស្សរិយយស **សហមេត្រី** ថ្នាក់ **មហាសេនា**

ចំពោះ

លោក Ben O'Reilly

ទីប្រឹក្សាអមស្ថានទូតអូស្ត្រាលី ប្រចាំព្រះរាជាណាចក្រកម្ពុជា

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៦
**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ពសរ. ២១០៥. ៥៥៥

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០៥២៦/៥៤៩

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីពន្ធនាគារ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១២១/០៣០ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ស្ដីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** លើកលែងទោសឱ្យទណ្ឌិតឈ្មោះ ស៊ូ អាហ៊ាហ្វាត់ ភេទប្រុស កើតឆ្នាំ១៩៧៥ ដែលត្រូវបានតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់រយៈពេល ៧ឆ្នាំ តាមអំណាចសាលដីកាព្រហ្មទណ្ឌស្ថាពរលេខ ៤០ ក្រV "វ" ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៣ របស់សាលាឧទ្ធរណ៍ភ្នំពេញ។

**មាត្រា២:** សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០២៦

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្ដីទី**

ភរស. ២៦០៥.៥៥៦

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់សុី**

# ព្រះរាជក្រឹត្យ

នស/រកត/០៥២៦/៥៥០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤ /១១៦៩ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤ /១៤៧៧ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនីទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១ :** ដំឡើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ចំពោះនាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ដែលបានទទួលមរណភាព ៖

**ក-ឋានន្តរស័ក្តិឧត្តមសេនីយ៍ទោ**

១-ឧត្តមសេនីយ៍ត្រី **ឈៀង ឃុន** អត្តលេខ ០០៣៦៤៤

២-ឧត្តមសេនីយ៍ត្រី **ជួន សារ៉េត** អត្តលេខ ០០២៨៧៦

**ខ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ត្រី**

១-វរសេនីយ៍ឯក **ប៉ក់ ឡា** អត្តលេខ ០១០៨២៤

២-វរសេនីយ៍ឯក **ហ៊ួយ ឈឿយ** អត្តលេខ ០១៩០០១

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

៣-វរសេនីយ៍ឯក **យង់ សារិ** អត្តលេខ ០០៤១៦១

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី *២៦* ខែ *ឧសភា* ឆ្នាំ២០២៦

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាប់ប្រមុខរដ្ឋស្តីទី**

*ពរស. ២៦០៥. ៥៥៧*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់សុី**

# ព្រះរាជក្រឹត្យ

នស/រកត/០៥២៦/៥៥៧

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៣៧ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីគោលការណ៍សម្រាប់ការតែងតាំងទីប្រឹក្សា និងជំនួយការនៅក្នុងអង្គការនីតិប្រតិបត្តិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំង និងផ្តល់ឋានៈឯកឧត្តម **ឈាម ពិសិដ្ឋ** ជាទីប្រឹក្សាអមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានឋានៈស្មើ អនុរដ្ឋលេខាធិការ។

**មាត្រា២:** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៦

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ពរស. ២៦០៥. ៥៦៤

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០៥២៦/៥៥៨

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

# ព្រះរាជក្រឹត្យ (final part)

**មាត្រា១ :** តាំងស៊ប់ទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងទៅក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដល់មន្ត្រីរាជការ ០៣ រូប ចាប់ពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៥ ៖

| | | |
|---|---|---|
| ១- លោកស្រី **ឌី ម៉ូសូលីដា** | អនុមន្ត្រី | ថ្នាក់លេខ ៤ |
| ២- លោក **ខូច សុជាតិ** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ៤ |
| ៣- លោក **ឌីមូ បញ្ញា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ៤ ។ |

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះរាជវាំង ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០២៦

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជា**

**ប្រមុខរដ្ឋស្តីទី**

ព.រ.ស. ២៦០៥. ៥៦៥

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០៥២៦/៥៥៩

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ដំឡើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** ដល់នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ២រូប៖

១-វរសេនីយ៍ឯក **ថោង សុខត្ថី** អត្តលេខ ៧៣៥៤៦

២-វរសេនីយ៍ឯក **មួរ ដាវិត** អត្តលេខ ៧៨១៤២។

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៦

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

ចារ.វេ. ២៦០៥. ៥៦៦

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថុរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០៥២៦/៥៦០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១២១/០៣០ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** លើកលែងទោសឱ្យទណ្ឌិតឈ្មោះ TANGUY EDDIE J TALLER ភេទប្រុស កើតឆ្នាំ១៩៨០ ដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់រយៈពេល អស់មួយជីវិត តាមអំណាចសាលក្រមព្រហ្មទណ្ឌស្ថាពរលេខ ០៦ "III" ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០២៣ របស់តុលាការកំពូល។

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០២៦

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

លេខៈ ២៦០៥. ៥៦២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់សុី**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៦៩ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០២ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ កំណត់អំពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ដើម្បីផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតប្រកបដោយគុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា២ .-**

ការផ្តល់អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតជាសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

## ជំពូកទី៣

## លក្ខខណ្ឌនៃការផ្តល់អាជ្ញាបណ្ណ

### ផ្នែកទី១

### ប្រភេទនៃអាជ្ញាបណ្ណ

**មាត្រា៣ .-**

អាជ្ញាបណ្ណមានពីរប្រភេទ៖

- អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត
- អាជ្ញាបណ្ណផ្គត់ផ្គង់ទឹកស្អាតប្រភេទលក់ដុំ។

**មាត្រា៤ .-**

អាជ្ញាបណ្ណត្រូវមានសុពលភាពជាក់លាក់ដែលកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

អាជ្ញាបណ្ណអាចត្រូវបន្ត ព្យួរ ដកហូត ឬលុបមុនពេលផុតកំណត់បាន។

បែបបទនិងបរិបថនៃការបន្ត ការព្យួរ ការដកហូត និងការលុបអាជ្ញាបណ្ណ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

### ផ្នែកទី២

### លក្ខខណ្ឌនៃការផ្តល់អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត

**មាត្រា៥ .-**

លក្ខខណ្ឌនៃការផ្តល់អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ត្រូវមានដូចខាងក្រោម៖

១- លទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាពគម្រោងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតក្នុងតំបន់ជាក់លាក់ណាមួយ លើកលែងតែតំបន់ណាមួយមានតម្រូវការចាំបាច់និងបន្ទាន់ក្នុងការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍មានសិទ្ធិសម្រេចលើកលែងការសិក្សាសមិទ្ធិលទ្ធភាព។

២- របាយការណ៍លទ្ធផលវិជ្ជមាននៃការវាយតម្លៃដោយគណៈកម្មាធិការវាយតម្លៃពាក្យស្នើសុំអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត។

៣- សមត្ថភាពហិរញ្ញវត្ថុនិងសមត្ថភាពបច្ចេកទេសក្នុងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព។

## ផ្នែកទី៣
## លក្ខខណ្ឌនៃការផ្តល់អាជ្ញាបណ្ណផ្គត់ផ្គង់ទឹកស្អាតប្រភេទលក់ដុំ

**មាត្រា៦ .-**

លក្ខខណ្ឌនៃការផ្តល់អាជ្ញាបណ្ណផ្គត់ផ្គង់ទឹកស្អាតប្រភេទលក់ដុំ ត្រូវមានដូចខាងក្រោម៖

១- លទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាពគម្រោងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតប្រភេទលក់ដុំ លើកលែងតែតំបន់ណាមួយ មានតម្រូវការចាំបាច់និងបន្ទាន់ក្នុងការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍មានសិទ្ធិសម្រេចលើកលែងការសិក្សាសមិទ្ធិលទ្ធភាព។

២- របាយការណ៍លទ្ធផលវិជ្ជមាននៃការវាយតម្លៃដោយគណៈកម្មាធិការវាយតម្លៃពាក្យស្នើសុំអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត។

៣- សមត្ថភាពហិរញ្ញវត្ថុនិងសមត្ថភាពបច្ចេកទេសក្នុងការផ្គត់ផ្គង់ទឹកស្អាតប្រភេទលក់ដុំប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព។

## ជំពូកទី៤
## នីតិវិធីនៃការផ្តល់អាជ្ញាបណ្ណ
## ផ្នែកទី១
## នីតិវិធីនៃការផ្តល់អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត

**មាត្រា៧ .-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលមានបំណងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតផ្តល់សិទ្ធិសិក្សាសមិទ្ធិលទ្ធភាពគម្រោងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតក្នុងតំបន់ជាក់លាក់ណាមួយ។ ទីតាំងភូមិសាស្ត្រនៃការសិក្សាសមិទ្ធិលទ្ធភាព ត្រូវកំណត់ដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ការសិក្សាសមិទ្ធិលទ្ធភាពគម្រោងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ត្រូវបង្ហាញទីតាំងភូមិសាស្ត្រ ស្ថានភាពប្រជាសាស្ត្រ ស្ថានភាពប្រភពទឹក ប្រសិទ្ធភាពសេដ្ឋកិច្ច សង្គម និងកត្តាចាំបាច់មួយចំនួនទៀត ដែលជាសូចនាករសំខាន់ៗសម្រាប់ធ្វើជាមូលដ្ឋាននៃការពិនិត្យវាយតម្លៃ។

បែបបទនិងនីតិវិធីនៃការស្នើសុំលិខិតអនុញ្ញាតផ្តល់សិទ្ធិសិក្សាសមិទ្ធិលទ្ធភាពគម្រោងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**មាត្រា៨ .-**

បន្ទាប់ពីសិក្សាសមិទ្ធិលទ្ធភាពរួចរាល់ រូបវន្តបុគ្គលឬនីតិបុគ្គលត្រូវរៀបចំដាក់ពាក្យស្នើសុំអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

**មាត្រា៩ .-**

ពាក្យស្នើសុំអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ត្រូវមានមូលវិចារណ៍ពីរដ្ឋបាលឃុំ សង្កាត់ និងមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍រាជធានី ខេត្ត នៃដែនសមត្ថកិច្ចរដ្ឋបាលតំបន់ផ្តល់សេវាកម្មនោះ។

**មាត្រា១០ .-**

រដ្ឋបាលឃុំ សង្កាត់នីមួយៗ ត្រូវពិនិត្យនិងផ្តល់យោបល់ រួចឆ្លើយតបក្នុងរយៈពេលយ៉ាងយូរ៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលពាក្យស្នើសុំអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត។

ក្នុងករណីរដ្ឋបាលឃុំ សង្កាត់ខកខានមិនបានពិនិត្យនិងផ្តល់យោបល់ក្នុងរយៈពេលដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ត្រូវចាត់ទុកថា រដ្ឋបាលឃុំ សង្កាត់បានយល់ព្រមជាគោលការណ៍ទៅលើពាក្យស្នើសុំ។

**មាត្រា១១ .-**

មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវមានមូលវិចារណ៍ឆ្លើយតបក្នុងរយៈពេលយ៉ាងយូរ៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានពាក្យស្នើសុំអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត។

ក្នុងករណីមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ខកខានមិនបានពិនិត្យនិងផ្តល់យោបល់ក្នុងរយៈពេលដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ត្រូវចាត់ទុកថា មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍បានយល់ព្រមជាគោលការណ៍ទៅលើពាក្យស្នើសុំ។

ក្នុងករណីពាក្យស្នើសុំអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតមិនបានបំពេញត្រឹមត្រូវនិងគ្រប់គ្រាន់តាមបែបបទ មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវឱ្យរូបវន្តបុគ្គលឬនីតិបុគ្គលធ្វើការកែតម្រូវនិងបំពេញឡើងវិញ ហើយមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវឆ្លើយតបក្នុងរយៈពេលយ៉ាងយូរ២(ពីរ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានពាក្យស្នើសុំដែលបានកែតម្រូវរួច។

**មាត្រា១២ .-**

រូបវន្តបុគ្គលឬនីតិបុគ្គលត្រូវយកពាក្យស្នើសុំអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដែលមានមូលវិចារណ៍រួចដាក់មកការិយាល័យច្រកចេញចូលតែមួយរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឬតាមប្រព័ន្ធឌីជីថល។

បន្ទាប់ពីទទួលបានពាក្យស្នើសុំអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវពិនិត្យលើសំណុំឯកសារ រួចត្រូវឆ្លើយតបក្នុងរយៈពេលយ៉ាងយូរ៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ តាមករណីដូចខាងក្រោម៖

១- ករណីសំណុំឯកសារបំពេញត្រឹមត្រូវនិងគ្រប់គ្រាន់តាមបែបបទ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវចេញបង្កាន់ដៃទទួលពាក្យស្នើសុំអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត រួចបញ្ជូនសំណុំឯកសារទៅគណៈកម្មាធិការវាយតម្លៃពាក្យស្នើសុំអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត។

២- ករណីសំណុំឯកសារមិនត្រឹមត្រូវនិងគ្រប់គ្រាន់តាមបែបបទ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវបញ្ជូនសំណុំឯកសារទៅអ្នកដាក់ពាក្យស្នើសុំ ដើម្បីកែតម្រូវឡើងវិញ។

**មាត្រា១៣ .-**

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវពិនិត្យនិងផ្តល់អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតក្នុងរយៈពេលយ៉ាងយូរ៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។ ក្នុងករណីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍បដិសេធមិនផ្តល់អាជ្ញាបណ្ណ ក្រសួងត្រូវបញ្ជាក់ពីមូលហេតុនៃការបដិសេធនោះ។

## ផ្នែកទី២
## នីតិវិធីនៃការផ្តល់អាជ្ញាបណ្ណផ្គត់ផ្គង់ទឹកស្អាតប្រភេទលក់ដុំ

**មាត្រា១៤ .-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលមានបំណងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតប្រភេទលក់ដុំ ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតផ្តល់សិទ្ធិសិក្សាសមិទ្ធិលទ្ធភាពគម្រោងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតប្រភេទលក់ដុំក្នុងតំបន់ជាក់លាក់ណាមួយ។ ទីតាំងភូមិសាស្ត្រនៃការសិក្សាសមិទ្ធិលទ្ធភាព ត្រូវកំណត់ដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ការសិក្សាសមិទ្ធិលទ្ធភាពគម្រោងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតប្រភេទលក់ដុំ ត្រូវបង្ហាញទីតាំងភូមិសាស្ត្រ តម្រូវការទឹកស្អាតដុំ ស្ថានភាពប្រភពទឹក ប្រសិទ្ធភាពសេដ្ឋកិច្ច សង្គម និងកត្តាចាំបាច់មួយចំនួនទៀត ដែលជាសូចនាករសំខាន់ៗសម្រាប់ធ្វើជាមូលដ្ឋាននៃការពិនិត្យវាយតម្លៃ។

បែបបទនិងនីតិវិធីនៃការស្នើសុំលិខិតអនុញ្ញាតផ្តល់សិទ្ធិសិក្សាសមិទ្ធិលទ្ធភាពគម្រោងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតប្រភេទលក់ដុំ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**មាត្រា១៥ .-**

បន្ទាប់ពីសិក្សាសមិទ្ធិលទ្ធភាពរួចរាល់ រូបវន្តបុគ្គលឬនីតិបុគ្គលត្រូវរៀបចំដាក់ពាក្យស្នើសុំអាជ្ញាបណ្ណផ្គត់ផ្គង់ទឹកស្អាតប្រភេទលក់ដុំមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា១៦ .-**

ពាក្យស្នើសុំអាជ្ញាបណ្ណផ្គត់ផ្គង់ទឹកស្អាតប្រភេទលក់ដុំ ត្រូវមានមូលវិចារណ៍ពីមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍រាជធានី ខេត្ត នៃដែនសមត្ថកិច្ចរដ្ឋបាលតំបន់ផ្តល់សេវាកម្មនោះ។

មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវមានមូលវិចារណ៍ឆ្លើយតបក្នុងរយៈពេលយ៉ាងយូរ៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានពាក្យស្នើសុំអាជ្ញាបណ្ណផ្គត់ផ្គង់ទឹកស្អាតប្រភេទលក់ដុំ។

ក្នុងករណីមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ខកខានមិនបានពិនិត្យនិងផ្តល់យោបល់ក្នុងរយៈពេលដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រានេះ ត្រូវចាត់ទុកថា មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍បានយល់ព្រមជាគោលការណ៍ទៅលើពាក្យស្នើសុំ។

ក្នុងករណីពាក្យស្នើសុំអាជ្ញាបណ្ណផ្គត់ផ្គង់ទឹកស្អាតប្រភេទលក់ដុំមិនបានបំពេញត្រឹមត្រូវនិងគ្រប់គ្រាន់តាមបែបបទ មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវឱ្យរូបវន្តបុគ្គលឬនីតិបុគ្គលធ្វើការកែតម្រូវនិងបំពេញឡើងវិញ ហើយមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ត្រូវឆ្លើយតបក្នុងរយៈពេលយ៉ាងយូរ២(ពីរ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានពាក្យស្នើសុំដែលបានកែតម្រូវរួច។

**មាត្រា១៧ .-**

រូបវន្តបុគ្គលឬនីតិបុគ្គលត្រូវយកពាក្យស្នើសុំអាជ្ញាបណ្ណផ្គត់ផ្គង់ទឹកស្អាតប្រភេទលក់ដុំដែលមានមូលវិចារណ៍រួចដាក់មកការិយាល័យច្រកចេញចូលតែមួយរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឬតាមប្រព័ន្ធឌីជីថល។

បន្ទាប់ពីទទួលបានពាក្យស្នើសុំអាជ្ញាបណ្ណផ្គត់ផ្គង់ទឹកស្អាតប្រភេទលក់ដុំ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវពិនិត្យលើសំណុំឯកសារ រួចត្រូវឆ្លើយតបក្នុងរយៈពេលយ៉ាងយូរ៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ តាមករណីដូចខាងក្រោម៖

១- ករណីសំណុំឯកសារបំពេញត្រឹមត្រូវនិងគ្រប់គ្រាន់តាមបែបបទ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវចេញបង្កាន់ដៃទទួលពាក្យស្នើសុំអាជ្ញាបណ្ណផ្គត់ផ្គង់ទឹកស្អាតប្រភេទលក់ដុំ រួចបញ្ជូនសំណុំឯកសារទៅគណៈកម្មាធិការវាយតម្លៃពាក្យស្នើសុំអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត។

២- ករណីសំណុំឯកសារមិនត្រឹមត្រូវនិងគ្រប់គ្រាន់តាមបែបបទ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវបញ្ជូនសំណុំឯកសារទៅអ្នកដាក់ពាក្យស្នើសុំ ដើម្បីកែតម្រូវឡើងវិញ។

**មាត្រា១៨ .-**

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវពិនិត្យនិងផ្តល់អាជ្ញាបណ្ណផ្គត់ផ្គង់ទឹកស្អាតប្រភេទលក់ដុំក្នុងរយៈពេលយ៉ាងយូរ៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។ ក្នុងករណីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍បដិសេធមិនផ្តល់អាជ្ញាបណ្ណ ក្រសួងត្រូវបញ្ជាក់ពីមូលហេតុនៃការបដិសេធនោះ។

## ជំពូកទី៥
## វិធីនៃការផ្តល់អាជ្ញាបណ្ណ

**មាត្រា១៩ .-**

ការផ្តល់អាជ្ញាបណ្ណ ត្រូវអនុវត្តតាមវិធីពីរគឺ៖

- វិធីប្រគល់ផ្ទាល់
- វិធីប្រកួតប្រជែង។

លក្ខណវិនិច្ឆ័យសម្រាប់កំណត់តំបន់ដែលជាកម្មវត្ថុនៃការផ្តល់អាជ្ញាបណ្ណតាមវិធីប្រគល់ផ្ទាល់ឬវិធីប្រកួតប្រជែង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

## ជំពូកទី៦
## គណៈកម្មាធិការវាយតម្លៃពាក្យស្នើសុំអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត

**មាត្រា២០ .-**

គណៈកម្មាធិការវាយតម្លៃពាក្យស្នើសុំអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត មានភារកិច្ចពិនិត្យ វាយតម្លៃ និងអនុម័តលើសំណុំឯកសារស្នើសុំអាជ្ញាបណ្ណ។

គណៈកម្មាធិការវាយតម្លៃពាក្យស្នើសុំអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត អាចមានទីប្រឹក្សាឯករាជ្យ និង/ឬជំនាញការបច្ចេកទេសដើម្បីជួយការងារតាមការចាំបាច់។

ការបង្កើត ការផ្លាស់ប្តូរ និងការកែសម្រួលសមាសភាពគណៈកម្មាធិការវាយតម្លៃពាក្យស្នើសុំអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**មាត្រា២១ .-**

រូបវន្តបុគ្គលដែលទទួលអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ត្រូវចុះបញ្ជីពាណិជ្ជកម្មដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៧
## ការប្រើប្រាស់ដីនិងប្រភពទឹក

**មាត្រា២២ .-**

ប្រតិបត្តិករអាចប្រើប្រាស់ដីសាធារណៈដើម្បីដំឡើងឬសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ដោយត្រូវគោរពតាមបទប្បញ្ញត្តិច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ចំពោះដីមានម្ចាស់កម្មសិទ្ធិស្របច្បាប់ ប្រតិបត្តិករត្រូវខិតខំដោះស្រាយតាមរយៈការចរចា សម្របសម្រួលជាមួយម្ចាស់កម្មសិទ្ធិ ដោយទូទាត់សំណងសមរម្យនិងយុត្តិធម៌ ដើម្បីមានសិទ្ធិចូល សិទ្ធិឆ្លងកាត់ និង/ឬប្រើប្រាស់ដីសម្រាប់ដំឡើង សាងសង់ ឬជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។

ក្នុងករណីដែលមិនអាចទទួលបានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ ប្រតិបត្តិករត្រូវស្នើសុំទៅអាជ្ញាធរមានសមត្ថកិច្ចដើម្បីដោះស្រាយបញ្ហានេះ ដើម្បីជាប្រយោជន៍សាធារណៈ។

**មាត្រា២៣ .-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំអាជ្ញាបណ្ណ ត្រូវសិក្សាពីជម្រើសនៃការប្រើប្រាស់ប្រភពទឹកទៅតាមទីតាំងភូមិសាស្ត្រជាក់ស្តែង។

ប្រតិបត្តិករអាចប្រើប្រាស់ប្រភពទឹកទៅតាមលក្ខណៈភូមិសាស្ត្រដែលអំណោយផលនិងតាមមធ្យោបាយដែលខ្លួនមានសម្រាប់ធ្វើប្រព្រឹត្តកម្ម។ រាល់ការប្រើប្រាស់ប្រភពទឹក ប្រតិបត្តិករត្រូវស្នើសុំការអនុញ្ញាតពីក្រសួង ស្ថាប័នមានសមត្ថកិច្ចដែលគ្រប់គ្រងប្រភពទឹកនោះ។ ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវសម្របសម្រួលដកទឹកពីប្រភពដល់ប្រតិបត្តិករ។

ការប្រើប្រាស់ប្រភពទឹកនេះ ត្រូវគោរពនិងធ្វើកិច្ចសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិនិង/ឬក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការគ្រប់គ្រង ថែរក្សា និងការពារប្រភពទឹក ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៨
## ការសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត

**មាត្រា២៤ .-**

ប្រតិបត្តិករដែលទទួលបានអាជ្ញាបណ្ណពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវធ្វើការសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ស្របតាមកម្មវិធីសាងសង់ និងអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសដែលក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍បានកំណត់។

បទប្បញ្ញត្តិបច្ចេកទេសក្នុងការសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ក្នុងករណីចាំបាច់ ប្រតិបត្តិករអាចដាក់ពាក្យស្នើសុំពន្យារពេលការសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍បាន ដោយមានបញ្ជាក់មូលហេតុសមស្រប។

បន្ទាប់ពីសាងសង់ប្រព័ន្ធប្រព្រឹត្តកម្មនិងរៀបចំប្រព័ន្ធបណ្តាញផ្គត់ផ្គង់ទឹកស្អាត ប្រតិបត្តិករត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

នីតិវិធីនៃការផ្តល់វិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

## ជំពូកទី៩
## ការស្នើសុំពង្រីកតំបន់សេវាកម្ម

**មាត្រា២៥ .-**

ការស្នើសុំពង្រីកតំបន់សេវាកម្ម អាចធ្វើទៅបានលុះត្រាតែៈ

- ប្រតិបត្តិករបានបំពេញផ្ទៃសេវាផ្គត់ផ្គង់ទឹកស្អាតក្នុងតំបន់របស់ខ្លួនយ៉ាងតិច៨០(ប៉ែតសិប)ភាគរយ
- ប្រតិបត្តិករបានអនុវត្តកម្មវិធីសាងសង់ប្រព័ន្ធប្រព្រឹត្តកម្មបាន១០០(មួយរយ)ភាគរយ តាមផែនការកំណត់ និង
- តំបន់សេវាកម្មដែលស្នើសុំពង្រីកមានព្រំប្រទល់ជាប់នឹងតំបន់ដែលប្រតិបត្តិករកំពុងផ្តល់សេវាទឹកស្អាត និងមិនទាន់មានអ្នកធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត។

បែបបទនិងបរិបថនៃការអនុញ្ញាតឱ្យពង្រីកតំបន់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

## ជំពូកទី១០
## ការបន្តសុពលភាពអាជ្ញាបណ្ណ

**មាត្រា២៦ .-**

អាជ្ញាបណ្ណ អាចបន្តសុពលភាពជាថ្មីបាន។

មុននឹងផុតសុពលភាពរយៈពេល៣(បី)ខែ ប្រតិបត្តិករត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណជាថ្មីឡើងវិញ។

ក្នុងករណីប្រតិបត្តិករមិនមានបំណងបន្តធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ប្រតិបត្តិករត្រូវចូលរួមសហការជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីធានានិរន្តរភាពនៃការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត។

## ជំពូកទី១១
## កម្រៃសេវាសាធារណៈ

**មាត្រា២៧ .-**

ការស្នើសុំអាជ្ញាបណ្ណ ត្រូវបង់កម្រៃសេវាសាធារណៈដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី១២
## អន្តរប្បញ្ញត្តិ

**មាត្រា២៨ .-**

ក្នុងរយៈពេលយ៉ាងយូរ៦(ប្រាំមួយ)ខែបន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវចេញអាជ្ញាបណ្ណទម្រង់ថ្មីជូនប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតដោយឥតគិតកម្រៃសេវាសាធារណៈនិងដោយរក្សានូវលក្ខខណ្ឌដដែល ដូចបានកំណត់នៅក្នុងប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត។

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវកែសម្រួលឡើងវិញនូវលក្ខខណ្ឌណាមួយជាមួយប្រតិបត្តិករ ក្នុងករណីដែលលក្ខខណ្ឌមានកំណត់នៅក្នុងប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតនោះមិនមានអនុលោមភាពពេញលេញតាមច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាតនិងបទប្បញ្ញត្តិជាធរមាននានាពាក់ព័ន្ធនឹងការគ្រប់គ្រងវិស័យទឹកស្អាត។

**មាត្រា២៩ .-**

បុគ្គលដែលបានដាក់ពាក្យស្នើសុំអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតរួចហើយមុនអនុក្រឹត្យនេះចូលជាធរមាន ត្រូវបន្តអនុវត្តតាមនីតិវិធីដូចមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការចេញ កែសម្រួល បន្ត ព្យួរ និងដកហូតប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដែលនៅជាធរមាន។

## ជំពូកទី១៣
## អវសានប្បញ្ញត្តិ

**មាត្រា៣០ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣១ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១១កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ**
**បច្ចេកវិទ្យា និងនវានុវត្តន៍**

**ហែម វណ្ណឌី**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១នៃអនុក្រឹត្យលេខ៦៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៦
ស្ដីពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្ដល់អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត

## ទម្រង់គំរូពាក្យស្នើសុំអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................... សញ្ជាតិ................ តួនាទី................................................
អាសយដ្ឋាន : ...........................................................................................................................
លេខអត្តសញ្ញាណបណ្ណ ( លិខិតឆ្លងដែន ) : ................................ ចុះថ្ងៃទី......... ខែ......... ឆ្នាំ...............
លេខទូរសព្ទទំនាក់ទំនង : .............................. លេខទូរសារ : ..................................................
អ៊ីមែល : ..................................................................................................................................
ឈ្មោះក្រុមហ៊ុន : ......................................................................................................................
អាសយដ្ឋានក្រុមហ៊ុន : ..............................................................................................................
លេខសម្គាល់( ដូចលេខសម្គាល់របស់ពាក្យស្នើសុំសិក្សា ) : .........................................................

**<u>សូមគោរពជូន</u>**
**ឯកឧត្តមរដ្ឋមន្ត្រី**
**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

**<u>កម្មវត្ថុ</u>** : ស្នើសុំអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដែលមានទីតាំងផលិតកម្មនៅភូមិ.......................
ឃុំ/សង្កាត់........................ ស្រុក/ខណ្ឌ....................... រាជធានី/ខេត្ត.........................

**<u>យោង</u>** : លិខិតអនុញ្ញាតឱ្យធ្វើការសិក្សាសមិទ្ធិលទ្ធភាពគម្រោងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លេខ : ............................ ចុះថ្ងៃ............. ខែ........................... ឆ្នាំ.............................. ព.ស. ...................... ត្រូវនឹងថ្ងៃទី.............. ខែ.......... ឆ្នាំ.............។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា : ក្រោយពីទទួលបានការអនុញ្ញាតរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យធ្វើការសិក្សាសមិទ្ធិលទ្ធភាពគម្រោងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដែលមានទីតាំងនៅភូមិ.......... ឃុំ/សង្កាត់................ ស្រុក/ខណ្ឌ...................... រាជធានី/ខេត្ត..................... និងមានតំបន់សេវាកម្មនៅចំនួន............. ភូមិស្ថិតក្នុងឃុំ/សង្កាត់ចំនួន....... គឺឃុំ/សង្កាត់................... ស្រុក/ខណ្ឌ...................... រាជធានី/ខេត្ត.................................

ខ្ញុំបាទ/នាងខ្ញុំ បានធ្វើការសិក្សាតាមសេចក្ដីណែនាំស្ដីពី**ការរៀបចំឯកសារសិក្សាសមិទ្ធិលទ្ធភាព**របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបានបញ្ចប់ការសិក្សារួចរាល់តាមកាលបរិច្ឆេទ។

ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជូនភ្ជាប់មកជាមួយឯកសារ ដូចខាងក្រោមៈ

១- ឯកសារសិក្សាសមិទ្ធិលទ្ធភាព ចំនួន៣ច្បាប់។

២- គម្រោងសាងសង់មធ្យោបាយផលិតកម្មនិងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតដោយមានបញ្ជាក់ប្រភពទុនវិនិយោគដោយស្មោះត្រង់និងគំនូសប្លង់បច្ចេកទេស ចំនួន៣ច្បាប់។

៣- កម្មវិធីសាងសង់មធ្យោបាយផលិតកម្មនិងប្រព័ន្ធបណ្តាញផ្គត់ផ្គង់ទឹកស្អាត ចំនួន៣ច្បាប់។
៤- ផែនការអាជីវកម្មរយៈពេល៥ឆ្នាំ ចំនួន៣ច្បាប់។
៥- វិញ្ញាបនបត្របញ្ជាក់លទ្ធផលវិភាគគុណភាពទឹកប្រភពរបស់មជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា ចំនួន៣ច្បាប់។
៦- មូលវិចារណ៍ពីរដ្ឋបាលឃុំ សង្កាត់និងមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានី ខេត្ត ចំនួន៣ច្បាប់។
៧- ផែនទីបង្ហាញអំពីតំបន់ស្នើសុំធ្វើប្រតិបត្តិការផ្គត់ផ្គង់ទឹកស្អាត(GPS) ចំនួន៣ច្បាប់។
៨- ផែនទីបណ្តាញទឹកស្អាត(GPS) ចំនួន៣ច្បាប់។
៩- ពាក្យស្នើសុំអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ចំនួន១ច្បាប់។
១០- របាយការណ៍ស្ថិតិប្រជាពលរដ្ឋក្នុងភូមិ/ឃុំ/សង្កាត់ ក្នុងតំបន់សេវាកម្ម ចំនួន៣ច្បាប់។
១១- ច្បាប់ថតចម្លងវិក្កយបត្រកម្រៃសម្រាប់ការស្នើសុំអាជ្ញាបណ្ណ ចំនួន១ច្បាប់។

| **ថ្លៃលក់ទឹកស្អាត( គិតជារៀល )** | | |
|---|---|---|
| កម្រិតប្រើប្រាស់ | ថ្លៃលក់ទឹក | ផ្សេងៗ |
| ចាប់ពី : ........................................ | | |
| ចាប់ពី : ........................................ | | |
| ចាប់ពី : ........................................ | | |
| ចាប់ពី : ........................................ | | |

| **ថ្លៃសេវាផ្សេងៗ( គិតជារៀល )** | | | | | | |
|---|---|---|---|---|---|---|
| ប្រាក់កក់ | ភ្ជាប់បណ្តាញ | ថៃទាំនាឡិកា | កម្រៃអប្បបរមា | ភ្ជាប់បណ្តាញឡើងវិញ | ពិន័យ | ផ្សេងៗ |
| | | | | | | |

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលជ្រាប និងពិនិត្យផ្តល់អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតឱ្យខ្ញុំបាទ/នាងខ្ញុំ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ ពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ........................ ខែ.............. ឆ្នាំ.................... ព.ស. ..........

......................... ថ្ងៃទី............ ខែ..............

**ស្នាមមេដៃឬហត្ថលេខា**

ឧបសម្ព័ន្ធទី២នៃអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៦
ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត

## ទម្រង់គំរូពាក្យស្នើសុំអាជ្ញាបណ្ណផ្គត់ផ្គង់ទឹកស្អាតប្រភេទលក់ដុំ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................. សញ្ជាតិ................ តួនាទី..........................................
អាសយដ្ឋាន : ......................................................................................................................
លេខអត្តសញ្ញាណបណ្ណ (លិខិតឆ្លងដែន) : ................................ ចុះថ្ងៃទី........ ខែ......... ឆ្នាំ...............
លេខទូរសព្ទទំនាក់ទំនង : ............................. លេខទូរសារ : ......................................................
អ៊ីមែល : ...............................................................................................................................
ឈ្មោះក្រុមហ៊ុន : ...................................................................................................................
អាសយដ្ឋានក្រុមហ៊ុន : ...........................................................................................................
លេខសម្គាល់(ដូចលេខសម្គាល់របស់ពាក្យស្នើសុំសិក្សា) : ..........................................................

**<u>សូមគោរពជូន</u>**
**ឯកឧត្តមរដ្ឋមន្ត្រី**
**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

**<u>កម្មវត្ថុ</u>** : ស្នើសុំអាជ្ញាបណ្ណផ្គត់ផ្គង់ទឹកស្អាតប្រភេទលក់ដុំដែលមានទីតាំងផលិតកម្មនៅភូមិ...................... ឃុំ/សង្កាត់........................ ស្រុក/ខណ្ឌ...................... រាជធានី/ខេត្ត.........................

**<u>យោង</u>** : លិខិតអនុញ្ញាតឱ្យធ្វើការសិក្សាសមិទ្ធិលទ្ធភាពគម្រោងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតប្រភេទលក់ដុំ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លេខ : ..................ចុះថ្ងៃ........... ខែ........................... ឆ្នាំ............................ ព.ស. ................... ត្រូវនឹងថ្ងៃទី................. ខែ.......... ឆ្នាំ............។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា : ក្រោយពីទទួលបានការអនុញ្ញាតរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យធ្វើការសិក្សាសមិទ្ធិលទ្ធភាពគម្រោងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតប្រភេទលក់ដុំដែលមានទីតាំងនៅ ភូមិ.................... ឃុំ/សង្កាត់................ ស្រុក/ខណ្ឌ......................... រាជធានី/ខេត្ត.......................... និងមានតំបន់សេវាកម្មនៅចំនួន.......... ភូមិស្ថិតក្នុងឃុំ/សង្កាត់ចំនួន........ គឺឃុំ/សង្កាត់............................ ស្រុក/ខណ្ឌ......................... រាជធានី/ខេត្ត..................................

ខ្ញុំបាទ/នាងខ្ញុំ បានធ្វើការសិក្សាតាមសេចក្តីណែនាំស្តីពី**ការរៀបចំឯកសារសិក្សាសមិទ្ធិលទ្ធភាព**របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបានបញ្ចប់ការសិក្សារួចរាល់តាមកាលបរិច្ឆេទ។

ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជូនភ្ជាប់មកជាមួយឯកសារ ដូចខាងក្រោម៖

១- ឯកសារសិក្សាសមិទ្ធិលទ្ធភាព ចំនួន៣ច្បាប់។
២- គម្រោងសាងសង់មធ្យោបាយផលិតកម្មនិងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតដោយមានរូបភាព[illegible]ការ ទុនវិនិយោគដោយស្មោះត្រង់និងគំនូសប្លង់បច្ចេកទេស ចំនួន៣ច្បាប់។

៣- កម្មវិធីសាងសង់មធ្យោបាយផលិតកម្មនិងប្រព័ន្ធបណ្តាញផ្គត់ផ្គង់ទឹកស្អាត ចំនួន៣ច្បាប់។
៤- ផែនការអាជីវកម្មរយៈពេល៥ឆ្នាំ ចំនួន៣ច្បាប់។
៥- វិញ្ញាបនបត្របញ្ជាក់លទ្ធផលវិភាគគុណភាពទឹកប្រភពរបស់មជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្ម កម្ពុជា ចំនួន៣ច្បាប់។
៦- មូលវិចារណ៍មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍រាជធានី ខេត្ត ចំនួន៣ច្បាប់។
៧- ផែនទីបង្ហាញអំពីតំបន់ស្នើសុំធ្វើប្រតិបត្តិការផ្គត់ផ្គង់ទឹកស្អាត(GPS) ចំនួន៣ច្បាប់។
៨- ផែនទីបណ្តាញទឹកស្អាត(GPS) ចំនួន៣ច្បាប់។
៩- ពាក្យស្នើសុំអាជ្ញាបណ្ណផ្គត់ផ្គង់ទឹកស្អាតប្រភេទលក់ដុំ ចំនួន១ច្បាប់។
១០- របាយការណ៍ស្ថិតិប្រជាពលរដ្ឋក្នុងភូមិ/ឃុំ/សង្កាត់ ក្នុងតំបន់សេវាកម្ម ចំនួន៣ច្បាប់។
១១- ច្បាប់ថតចម្លងវិក្កយបត្រកម្រៃសម្រាប់ការស្នើសុំអាជ្ញាបណ្ណ ចំនួន១ច្បាប់។

| **ថ្លៃលក់ទឹកស្អាត** (គិតជារៀល) | | |
|---|---|---|
| **កម្រិតប្រើប្រាស់** | **ថ្លៃលក់ទឹក** | **ផ្សេងៗ** |
| ចាប់ពី : ........................................ | | |
| ចាប់ពី : ........................................ | | |
| ចាប់ពី : ........................................ | | |
| ចាប់ពី : ........................................ | | |

| **ថ្លៃសេវាផ្សេងៗ**(គិតជារៀល) | | | | | | |
|---|---|---|---|---|---|---|
| **ប្រាក់កក់** | **ភ្ជាប់បណ្តាញ** | **ថែទាំ នាឡិកា** | **កម្រៃ អប្បបរមា** | **ភ្ជាប់បណ្តាញ ឡើងវិញ** | **ពិន័យ** | **ផ្សេងៗ** |
| | | | | | | |

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលជ្រាប និងពិនិត្យផ្តល់អាជ្ញាបណ្ណផ្គត់ផ្គង់ទឹកស្អាតប្រភេទលក់ដុំឱ្យខ្ញុំបាទ/នាងខ្ញុំ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ ពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ.........................ខែ............. ឆ្នាំ.................... ព.ស. ..........

.........................ថ្ងៃទី............ខែ.......................ឆ្នាំ............

**ស្នាមមេដៃឬហត្ថលេខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៣៧៧ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## សម្រេច

**មាត្រា១ ._**

ត្រូវបានបំពាក់មេដាយ **ការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ចំនួន ៩៩រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ **មាសការងារ**

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ឋោង សុពីមករា | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | |
| ២-លោក | អ៊ិន សុវណ្ណ | ប្រធាននាយកដ្ឋានបរិវត្តកម្មរដ្ឋាភិបាលឌីជីថល | |
| ៣-លោក | ញ៉ែត ទូ | អនុប្រធានមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តកំពត | |
| ៤-លោក | ឃ្លោក ពៅ | ប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តព្រះសីហនុ។ | |

ខ-មេដាយ **ប្រាក់ការងារ**

| | | |
|---|---|---|
| ១-លោក | ង៉ែត យូដារិត | អនុប្រធានវិទ្យាស្ថានបច្ចេកវិទ្យាឌីជីថល នៃបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា |
| ២-លោក | គី សៅរិទ្ធ | អនុប្រធាននាយកដ្ឋានគោលនយោបាយបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន |
| ៣-លោកស្រី | ហេង បញ្ញាវី | អនុប្រធានមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តព្រៃវែង |
| ៤-លោក | សាន់ សាំង | អនុប្រធានមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តសៀមរាប |
| ៥-លោកស្រី | ភី វណ្ណា | ប្រធានការិយាល័យ នៃនាយកដ្ឋានរដ្ឋបាល |
| ៦-លោកស្រី | ទឹម ឥណ្ឌាប៉ា | ប្រធានការិយាល័យ នៃនាយកដ្ឋានរដ្ឋបាល |
| ៧-លោក | ទូន សុឃន់ | ប្រធានការិយាល័យ នៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| ៨-លោកស្រី | សេង ស៊ីណា | ប្រធានការិយាល័យ នៃនាយកដ្ឋាននីតិកម្ម |
| ៩-លោក | សាន សេរី | ប្រធានការិយាល័យ នៃនាយកដ្ឋានគោលនយោបាយទូរគមនាគមន៍ |
| ១០-លោកស្រី | ញាន កន្និកា | ប្រធានការិយាល័យ នៃនាយកដ្ឋានគោលនយោបាយទូរគមនាគមន៍ |
| ១១-លោកស្រី | ជួរ សុជាតា | ប្រធានការិយាល័យ នៃនាយកដ្ឋានអធិការកិច្ចបច្ចេកទេស |
| ១២-លោក | ស៊ុន សុភ័ក្ត | ប្រធានការិយាល័យ នៃនាយកដ្ឋានគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិនិងគ្រប់គ្រងប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាល |
| ១៣-លោក | គុន សំណាង | ប្រធានការិយាល័យ នៃនាយកដ្ឋានគោលនយោបាយបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន |
| ១៤-លោក | វ៉ាន់ ជារិន | ប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តកំពង់ធំ |
| ១៥-លោក | ម៉ាក់ សាររដ្ឋ | ប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តបាត់ដំបង |
| ១៦-លោក | រិន សុផល | ប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តបាត់ដំបង |
| ១៧-លោក | មាស ពុទ្ធិសី | ប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តប៉ៃលិន |
| ១៨-លោក | ប៉ក់ សុជា | អនុប្រធានការិយាល័យ នៃនាយកដ្ឋានរដ្ឋបាល |
| ១៩-លោក | វុធ សក្កដា | អនុប្រធានការិយាល័យ នៃនាយកដ្ឋានរដ្ឋបាល |
| ២០-លោក | សៀ ជាលាភ | អនុប្រធានការិយាល័យ នៃនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល |
| ២១-លោក | ពេជ បញ្ញាវុធ | អនុប្រធានការិយាល័យ នៃនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល |
| ២២-លោក | ថៃ សុខលាង | អនុប្រធានការិយាល័យ នៃនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល |
| ២៣-លោកស្រី | ហ៊ត ស្រីនីត | អនុប្រធានការិយាល័យ នៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| ២៤-លោក | សេម ពិសិដ្ឋ | អនុប្រធានការិយាល័យ នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ២៥-លោក | ឡុង សុខឃីន | អនុប្រធានការិយាល័យ នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ២៦-លោក | ដួង គឹមហួរ | អនុប្រធានការិយាល័យ នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ២៧-លោក | អ៊ឹម សុវណ្ណនី | អនុប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តកំពង់ធំ |
| ២៨-លោក | នាង អង្គារទ្ធី | អនុប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តតាកែវ |
| ២៩-លោកស្រី | ប៉េង ច័ន្ទសុវណ្ណមន្នី | អនុប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តស្ទឹងត្រែង |

| | | |
|---|---|---|
| ៣០-លោកស្រី | ថៃ សាវន | មន្ត្រី នៃនាយកដ្ឋានរដ្ឋបាល |
| ៣១-លោក | ចាប សុមេធ | មន្ត្រី នៃនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល |
| ៣២-លោកស្រី | លី សុខហ៊ួច | មន្ត្រី នៃនាយកដ្ឋានគោលនយោបាយប្រៃសណីយ៍ |
| ៣៣-លោកស្រី | ឯក ឈុនណារី | មន្ត្រី នៃនាយកដ្ឋានគ្រប់គ្រង និងនិយ័តកម្មប្រៃសណីយ៍ឯកជន។ |

គ-មេដាយ **សំរឹទ្ធការងារ**

| | | |
|---|---|---|
| ១-លោក | ឌុច ឌីនីល | ព្រឹទ្ធបុរសរងមហាវិទ្យាល័យវិស្វកម្មឌីជីថល នៃបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា |
| ២-លោក | កែវ សាលី | ប្រធានដេប៉ាតឺម៉ង់វិទ្យាសាស្ត្រកុំព្យូទ័រ នៃបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា |
| ៣-លោក | គឹម វិសាល | អនុប្រធាននាយកដ្ឋានឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន |
| ៤-លោកស្រី | សួស មុន្នីរ៉ែដា | អនុប្រធាននាយកដ្ឋាននិយ័តកម្មទូរគមនាគមន៍ |
| ៥-លោក | ផន ដារ៉ូ | អនុប្រធាននាយកដ្ឋាននីតិកម្ម |
| ៦-លោកស្រី | ឈឺន ស្រីណារ | ប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តពោធិ៍សាត់ |
| ៧-លោកស្រី | ចាន់ មាលា | ប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តព្រៃវែង |
| ៨-លោក | ណៃ គោត្តមបុទុមា | ប្រធានការិយាល័យ នៃនាយកដ្ឋាននីតិកម្ម |
| ៩-លោក | កឿ សីហា | ប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តបន្ទាយមានជ័យ |
| ១០-លោក | ម៉ាក់ ហ៊ាងសំបូរ | អនុប្រធានការិយាល័យ នៃនាយកដ្ឋាននិយ័តកម្មទូរគមនាគមន៍ |
| ១១-លោក | សៀក សីហា | អនុប្រធាននាយកដ្ឋានរដ្ឋបាល នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល |
| ១២-លោកស្រី | ហឿន ច័ន្ទមករា | អនុប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តកោះកុង |
| ១៣-លោកស្រី | ពេជ្រ ថារី | អនុប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តកំពង់ឆ្នាំង |
| ១៤-លោកស្រី | ហាក់ ឌួងធីតា | អនុប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តពោធិ៍សាត់ |
| ១៥-លោក | ស៊ឹម ព្រៀម | អនុប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តតាកែវ |
| ១៦-លោកស្រី | កាក់ កញ្ញាកា | អនុប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តបន្ទាយមានជ័យ |
| ១៧-លោក | ហ៊ុត សុខហៀម | អនុប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តសៀមរាប |
| ១៨-លោក | ភូ ប៊ុនថាន់ | អនុប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តរតនគិរី |
| ១៩-លោក | ឈឿង មឿយ | អនុប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តឧត្តរមានជ័យ |

| | | |
|---|---|---|
| ២០-លោក | ឆាន ពេជ្ររ័ត្ន | អនុប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តឧត្តរមានជ័យ |
| ២១-លោកស្រី | គីម ស្រីរ័ត្ន | អនុប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តត្បូងឃ្មុំ |
| ២២-លោក | ម៉ី សារ៉េត | អនុប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តត្បូងឃ្មុំ |
| ២៣-លោក | រិទ្ធ វាសនា | អនុប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តពោធិ៍សាត់ |
| ២៤-លោក | ឡុយ ឃីត | អនុប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តឧត្តរមានជ័យ |
| ២៥-លោកស្រី | ផុន ស្រីលក្ខ | អនុប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តកែប |
| ២៦-លោក | ឈុន បញ្ញា | អនុប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តតាកែវ |
| ២៧-លោក | ឆេង រិទ្ធី | អនុប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តព្រៃវែង |
| ២៨-លោកស្រី | ទូន សោភ័ណ្ឌ | អនុប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តព្រៃវែង |
| ២៩-លោកស្រី | ស្រ៊ាង ម៉ារីយ៉ា | អនុប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តព្រៃវែង |
| ៣០-លោក | ហឿង វ៉ាឌុន | អនុប្រធានការិយាល័យ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តព្រៃវែង |
| ៣១-លោក | ស្រុង បញ្ញារិទ្ធ | មន្ត្រី នៃនាយកដ្ឋានរដ្ឋបាល |
| ៣២-លោកស្រី | សុខ ឆេងលាភ | មន្ត្រី នៃនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល |
| ៣៣-លោកស្រី | គីម បញ្ញា | មន្ត្រី នៃនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល |
| ៣៤-លោកស្រី | លន សក្ការា | មន្ត្រី នៃនាយកដ្ឋានផែនការ និងហិរញ្ញវត្ថុ |
| ៣៥-លោក | សេង ពិសិដ្ឋ | មន្ត្រី នៃនាយកដ្ឋានផែនការ និងហិរញ្ញវត្ថុ |
| ៣៦-លោកស្រី | ស៊ា វួចអ៊ី | មន្ត្រី នៃនាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុ |
| ៣៧-លោក | ស្រៀម ធឿម | មន្ត្រី នៃនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានសម្រាប់ជនបទ |
| ៣៨-លោក | អ៊ុក វិសាល | មន្ត្រី នៃនាយកដ្ឋានសន្តិសុខបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន |
| ៣៩-លោក | ឈួន សុភម៉ានិត | មន្ត្រី នៃមជ្ឈមណ្ឌលស្រាវជ្រាវគោលនយោបាយឌីជីថល |
| ៤០-លោក | នេត សុវណ្ណដារា | មន្ត្រី នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល |
| ៤១-លោក | ឃី សុវុទ្ធា | មន្ត្រី នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល |
| ៤២-លោក | ចាន់ ថៃលី | មន្ត្រី នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល |
| ៤៣-លោកស្រី | ខៀវ ចរិយា | មន្ត្រី នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តកណ្តាល |
| ៤៤-លោក | អ៊ុក តារាវុធ | មន្ត្រី នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តកណ្តាល |
| ៤៥-លោក | រៀង សុភ័ក្ត្រ | មន្ត្រី នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តកំពង់ចាម |
| ៤៦-លោក | សុខ វុទ្ធី | មន្ត្រី នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តកំពង់ចាម |
| ៤៧-លោកស្រី | ម៉ុត ពិសី | មន្ត្រី នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តកំពង់ឆ្នាំង |
| ៤៨-លោកស្រី | ឡាច ស្រីនាង | មន្ត្រី នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តកំពង់ស្ពឺ |
| ៤៩-លោកស្រី | ស្ងួន មករា | មន្ត្រី នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តកំពង់ស្ពឺ |
| ៥០-លោកស្រី | ឃូ តិចហួយ | មន្ត្រី នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តក្រចេះ |
| ៥១-លោកស្រី | គង់ ណារីន | មន្ត្រី នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តក្រចេះ |

| | | |
|---|---|---|
| ៥២-លោក | យឹម ប៉ូលី | មន្ត្រី នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តមណ្ឌលគិរី |
| ៥៣-លោក | ជីវ យ៉ាង | មន្ត្រី នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តកែប |
| ៥៤-លោក | ច័ន្ទ ពុទ្ធិដារ័ត្ន | មន្ត្រី នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តក្រចេះ |
| ៥៥-លោក | សែត នឿន | មន្ត្រី នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តកែប |
| ៥៦-លោកស្រី | សេ រ៉ដ្ឋេល | មន្ត្រី នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តកែប |
| ៥៧-លោកស្រី | ខៀវ ជីវា | មន្ត្រី នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តកែប |
| ៥៨-លោក | ញ៉ិល សៅសំរេច | មន្ត្រី នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តតាកែវ |
| ៥៩-លោកស្រី | ម៉េង ស្រីល័ក្ខ | មន្ត្រី នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តតាកែវ |
| ៦០-លោក | ជា សុវណ្ណារិទ្ធ | មន្ត្រី នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តតាកែវ |
| ៦១-លោកស្រី | ទឹម សឿនលក្ខិណា | មន្ត្រី នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តតាកែវ |
| ៦២-លោក | លិន គារុជ | មន្ត្រី នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តតាកែវ។ |

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៨កើត ខែ ពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ មេសា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៣៧៨ អនក្រ.តត

**អនុក្រឹត្យ**

**ស្តីពីការផ្តល់មេដាយសុវត្ថារា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១ .-**

ត្រូវបានបំពាក់មេដាយ **សុវត្ថារា** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ៤រូប ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ **សុវត្ថារា** ថ្នាក់ **ធិបឌិន្ទ**

១-វរសេនីយ៍ទោ មាស តារ៉ា

២-វរសេនីយ៍ឯក ប៉ូច ងន់សេង។

ខ-មេដាយ **សុវត្ថារា** ថ្នាក់ **សេនា**

១-លោក ណាង ស៊ាងហេង

២-លោក ម៉ៅ វ៉ាវៀត។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៨កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៣៧៤៩...អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនសប្បុរសជន ចំនួន ៤រូប ដូចមានរាយនាមខាងក្រោម៖

១-វរសេនីយ៍ត្រី ប៊ូ សុធារ៉ា

២-លោក អ៊ុក សុជា

៣-លោក ញ៉ឹក វាសនា

៤-លោក តាន់ សេង។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៨កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៣៨០ អនក្រ.គត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ពានជាតិ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់មេដាយ **ស្ពានជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ៩៨រូប ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ **មាសស្ពានជាតិ**

១-លោកអាចារ្យ រស់ រ៉ន

២-លោកអាចារ្យ ស ហៀង

៣-លោកអាចារ្យ ផាន់ ដោក

៤-លោកអាចារ្យ ម៉ៃ មឿន

៥-លោកអាចារ្យ ឡៀង លិស

៦-ឧបាសក ឯក ណែម

៧-ឧបាសក ម៉ៅ ឈីម
៨-ឧបាសក ឆែម ឆន
៩-ឧបាសក ឌី វន
១០-ឧបាសក នួន សម្បត្តិ
១១-ឧបាសក តាំង គីមហេង
១២-ឧបាសក អ៊ុន អ៊ី
១៣-ឧបាសក ជួន ឈិត
១៤-ឧបាសក ញ៉ែម ញឿន
១៥-ឧបាសិកា ជុំ ញ៉េស
១៦-ឧបាសិកា ឈួន យ៉េី
១៧-ឧបាសក សេង ម៉ូវ
១៨-ឧបាសក ជូ វន
១៩-លោក ហាក់ ភាព៉
២០-ឧបាសិកា ថុង ស្រៀង
២១-ឧបាសិកា អ៊ីន ពៅ
២២-លោក ជួន សុភា
២៣-អនុសេនីយ៍ឯក ឯក ឧត្តម
២៤-លោក កែវ ច័ន្ទណារុន
២៥-លោក ហុក គីមហេង
២៦-អនុសេនីយ៍ត្រី ស៊ិន សង្ហា
២៧-លោក វ៉ាន់ បណ្ឌិតបុត្រ
២៨-អនុសេនីយ៍ត្រី យូ រដ្ឋា
២៩-ព្រឹន្ទបាលទោ ដៅ ឡេង
៣០-អនុសេនីយ៍ត្រី ហុង ជាវុទ្ធ
៣១-អ្នកអង្គម្ចាស់បណ្ឌិត ស៊ីសុវត្ថិ ឫទ្ធីរ៉ាវង្ស
៣២-អនុសេនីយ៍ឯក សឿង សាមីត
៣៣-អនុសេនីយ៍ទោ ទេព ប៊ុនយ៉ុង។

ខ-មេដាយ **ប្រាក់ស្ថាបនាជាតិ**

១-ឧបាសក សេង ផាត
២-ឧបាសក លឿង វ៉េត
៣-ឧបាសក ឆៃ ឈឿន
៤-លោក ពាង ផាន្នី
៥-ឧបាសិកា អ៊ុច ម៉ិច
៦-ឧបាសិកា ស្រី យាត
៧-ឧបាសិកា ស្រី យឿង
៨-ឧបាសិកា សាត់ ម៉ុន

៩-ឧបាសក ឆៃ ឆុន
១០-ឧបាសក ដាំ មុយ
១១-ឧបាសិកា ព្រុំ ឡា
១២-ឧបាសិកា អិន មួន
១៣-ឧបាសក ពេជ្រ ហ៊ិន
១៤-ឧបាសក កាន់ ថុល
១៥-ឧបាសក សៀន សៃ
១៦-ឧបាសក រី សំអាង
១៧-ឧបាសិកា អ៊ុច សុន
១៨-ឧបាសក មាយ សាយ
១៩-ឧបាសិកា លន់ តាំងគីម
២០-ឧបាសក ចាន់ ចក់
២១-ឧបាសិកា ឡាង ស៊ីផាត
២២-ឧបាសិកា ហែម ឈាង
២៣-ឧបាសិកា ហែម ឈឿន
២៤-ឧបាសិកា សៀង គីមឈុន
២៥-ឧបាសក ឌុំ ឡឿន
២៦-ឧបាសិកា ជាវ ថាវី
២៧-វរសេនីយ៍ត្រី ឆោម កក្កដា
២៨-វរសេនីយ៍ត្រី អេម ជា
២៩-វរសេនីយ៍ត្រី ស្រ៊ឹ ចិត្ត
៣០-ឧបាសក ផង់ ចយ
៣១-ឧបាសក ឆាយ ធិល
៣២-ឧបាសក ពួន ឡេង
៣៣-ឧបាសក ស៊ុំ ស៊ិន
៣៤-ឧបាសិកា វ៉ៃ ខន
៣៥-ឧបាសិកា លន សុធារី
៣៦-លោកស្រី សេង គីមស៊ី
៣៧-វរសេនីយ៍ត្រី អ៊ូ ស៊ីដេត
៣៨-វរសេនីយ៍ត្រី គាន ខាន់វ៉ាន់ដា
៣៩-ឧបាសក ចក់ សារឿន។

គ-មេដាយ **សំរឹទ្ធស្ថាបនាជាតិ**

១-ឧបាសក ហ៊ួន ហ៊ុន
២-ឧបាសក នៅ ហៀក
៣-ឧបាសិកា ចេន អៃ
៤-ឧបាសិកា ជ្រុន ឈីវ

៥-ឧបាសិកា យូ សុខលី
៦-ឧបាសិកា យូ ស៊ីម៉ុន
៧-ឧបាសក ពន ឃា
៨-ឧបាសក ញ៉ឹក យូ
៩-ឧបាសក ញ៉ឹក ញ៉េប
១០-ឧបាសក គី ខេន
១១-ឧបាសិកា មុត ស៊ឹង
១២-ឧបាសិកា អ៊ិត ម៉ុក
១៣-ឧបាសិកា យី ប៉ុក
១៤-ឧបាសក ញ៉ឹក លឿន
១៥-ឧបាសក ញែម ឡុញ
១៦-ឧបាសក ស៊ឹង សឿន
១៧-ឧបាសក ផាន់ ត្រឹង
១៨-ឧបាសិកា ឡាង យ៉ុន
១៩-ឧបាសិកា ញ៉ឹក គីមអេង
២០-ឧបាសិកា ចក់ ផល្លីម
២១-ឧបាសិកា ផេង ចាន់ផល
២២-ឧបាសិកា អោក ណាង
២៣-ឧបាសិកា វ៉ាន់ រី
២៤-ឧបាសិកា ហេង ម៉ៅ
២៥-ឧបាសក សេង ស៊ាន់
២៦-អនុសេនីយ៍ត្រី វ៉ាត ច័ន្ទវិសាល។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៨កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៣៨១ អនក្រ.តត

## អនុក្រឹត្យ
## ស្ដីពីការជូនមេដាយសហមេត្រី
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់អនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

**មាត្រា១ .-**

ត្រូវបានបំពាក់មេដាយ **សហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនលោកស្រី CHOI Moon Jung ប្រធានទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ( KOICA )ប្រចាំកម្ពុជា ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច នៃព្រះរាជាណាចក្រកម្ពុជា កន្លងមក។

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៨កើត ខែ ពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៣៨៧...អនក្រ.តត

# អនុក្រឹត្យ
# ស្តីពី
# ការកែសម្រួលសមាសភាពក្រុមប្រឹក្សាភិបាល នៃបេឡាជាតិសន្តិសុខសង្គម អាណត្តិទី២

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការវិសោធនកម្មមាត្រា ៩ និងមាត្រា ១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២៥/០៤០ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលឱ្យស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣ នៃអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៤៥ អនក្រ.បក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ ស្តីពីគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈ
- បានឃើញប្រកាសលេខ៥៤៤ សហវ.ប្រក ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិការបស់អង្គភាពថវិកា
- បានឃើញប្រកាសលេខ ១១៥៨ សហវ.ប្រក.អរតន ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ ថ្នាក់សេដ្ឋកិច្ចនៃមាតិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ៩៧៤ សហវ.ប្រក.អរតន ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរដ្ឋទេយ្យចំណូលសម្រាប់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ១០៦៥ សហវ.ប្រក.អថ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការប្រគល់កាតព្វកិច្ចប្រមូលចំណូលថវិកាថ្នាក់ជាតិ សម្រាប់ឆ្នាំ២០២៦
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**ប្រការ ១.**_

ត្រូវបានបង្កើតរដ្ឋទេយ្យចំណូលនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីធ្វើការប្រមូលចំណូលមិនមែនសារពើពន្ធផ្សេងៗ។ បញ្ជីរាយមុខសញ្ញាចំណូលដែលរដ្ឋទេយ្យករត្រូវបានអនុញ្ញាតឱ្យប្រមូលមានដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. | អនុគណនី៧៣០២៣ | ផលពីការបង្កើតសហគ្រាស | ចំនួនទឹកប្រាក់ | ២ ២០០ ០០០ ០០០៛០០ |
| ២. | អនុគណនី៧៣០៤៣ | សេវាសុរិយោដី | ចំនួនទឹកប្រាក់ | ១៣៨ ៨៦៨ ០០០ ០០០៛០០ |
| ៣. | អនុគណនី៧៣០៤៤ | សេវាសំណង់ | ចំនួនទឹកប្រាក់ | ១៦ ០០០ ០០០ ០០០៛០០ |
| ៤. | អនុគណនី៧៣០៤៨ | ផលពីសេវាផ្សេងៗទៀត | ចំនួនទឹកប្រាក់ | ២០០ ០០០ ០០០៛០០ |
| ៥. | អនុគណនី៧៣០៦៦ | ចំណូលពីអាជ្ញាបណ្ណក្នុងស្រុក | ចំនួនទឹកប្រាក់ | ២៦ ០០០ ០០០៛០០ |
| | | | **សរុបទឹកប្រាក់៖** | **១៥៧ ២៩៤ ០០០ ០០០៛០០** |

**ប្រការ ២._**

ចំនួនទឹកប្រាក់អតិបរមាដែលអនុញ្ញាតទុកនៅបេឡាមានកំណត់ត្រឹមចំនួន ២ ០០០ ០០០៛០០ (ពីរលានរៀលគត់)។

**ប្រការ ៣._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៤._**

អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ អគ្គាធិការ ប្រធានអង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ ដូចមានចែងក្នុងប្រការ១ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**សាយ សំអាល់**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ២៣៦ ...... សហវ.ប្រក.

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបង្កើតរដ្ឋលេខាធិការដ្ឋានចំណូលនៅក្រសួងទេសចរណ៍

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០នៃច្បាប់ពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២៥/០៤០ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលឱ្យស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ ស្តីពីគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ២៥៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦
- បានឃើញបទបញ្ជាលេខ ០៤ បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញប្រកាសលេខ ៥៤៤ សហវ.ប្រក ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីសិទ្ធិអំណាចការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិការបស់អង្គភាពថវិកា
- បានឃើញប្រកាសលេខ ៩៧៤ សហវ.ប្រក.អរតន ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់ក្រសួងស្ថាប័ន អង្គភាពប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១១៥៨ សហវ.ប្រក.អរតន ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ៧៧២ សហវ.ប្រក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១០៦៥ សហវ.ប្រក.អថ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការប្រគល់កាតព្វកិច្ចប្រមូលចំណូលថវិកាជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងទេសចរណ៍

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតរជ្ជទេយ្យចំណូលនៅក្រសួងទេសចរណ៍ ដើម្បីធ្វើការប្រមូលចំណូលមិនមែនសារពើពន្ធផ្សេងៗ អនុលោមតាមបទប្បញ្ញត្តិជាធរមាន។ បញ្ជីរាយប្រភេទចំណូលដែលត្រូវបង្កើតរជ្ជទេយ្យចំណូលឆ្នាំ២០២៦ មានដូចខាងក្រោម៖

| | | |
|---|---|---|
| ១.អនុគណនី ៧៣០៦៦ | ចំណូលពីអាជ្ញាបណ្ណក្នុងស្រុក | ២ ៧០០ ០០០ ០០០រៀល |
| ២.អនុគណនី ៧៣០៨៧ | ចំណូលពីការត្រួតពិនិត្យគុណភាព ផលិតផល និងការគោរពបទដ្ឋាន | ១៥០ ០០០ ០០០រៀល |
| ៣.អនុគណនី ៧៤០១២ | ចំណូលពីការពិន័យ និងការដាក់ទណ្ឌកម្ម ពិន័យជាប្រាក់ | ៦០ ០០០ ០០០រៀល |
| | **សរុបទឹកប្រាក់៖** | **២ ៩១០ ០០០ ០០០រៀល** |

**ប្រការ២.-**

ចំនួនទឹកប្រាក់អតិបរមាដែលអនុញ្ញាតទុកនៅក្នុងបេឡាមានកំណត់ត្រឹមចំនួន ២ ០០០ ០០០រៀល (ពីរលានរៀលគត់)។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៤.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងទេសចរណ៍ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ៤ រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមករា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**ហួត ហាក់**

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៣៤៤ សហវ.ប្រក.អបជ

ក្រសួងមហាផ្ទៃ

ទីស្តីការគណៈរដ្ឋមន្ត្រី
ចូល
លេខ 2560
ថ្ងៃទី 22 ខែ 05 ឆ្នាំ 26
ម៉ោង 10H 33

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបែងចែកចំណូលពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- បានឃើញអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីគោលការណ៍ និងនីតិវិធីបន្ថែមសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធក្នុងក្របខ័ណ្ឌនៃការផ្ទេរមុខងារ និងការបែងចែកចំណូលមិនមែនសារពើពន្ធ ពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសអន្តរក្រសួងលេខ ៣៤៣ សហវ.ប្រក.អទច ចុះថ្ងៃទី[illegible] ខែមករា ឆ្នាំ២០២៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ចំណូលពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលប្រមូលបានដោយអនុវត្តតាមប្រកាសអន្តរក្រសួងលេខ ៣៤៣ ...សហវ.ប្រក.អទច ចុះថ្ងៃទី...[illegible] ខែមករា ឆ្នាំ២០២៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានបែងចែកទៅតាមអត្រាជាភាគរយធៀបនឹងចំណូលប្រមូលបានដូចខាងក្រោម ៖

| លេខរៀង | បរិយាយ | អត្រាបែងចែកចំណូល | | | | |
|---|---|---|---|---|---|---|
| | | បង់ចូលថវិកា រ.កសខ | រង្វាន់ រ.កសខ | រង្វាន់ រ.យស | រង្វាន់ ម.សហវ | រង្វាន់ អ.រប នៃ ក.មផ |
| ក- | ចំណូលពីការផ្តល់សេវារដ្ឋបាលលើការងារនីត្យានុកូលកម្ម ដែលប្រមូលបានដោយ | | | | | |
| ១- | រដ្ឋបាលខណ្ឌ | ២៩% | ៦៩% | ០% | ១% | ១% |
| ២- | រដ្ឋបាលក្រុង | ១៩% | ៧៩% | ០% | ១% | ១% |
| ៣- | រដ្ឋបាលស្រុក | ៩% | ៨៩% | ០% | ១% | ១% |

| លេខរៀង | បរិយាយ | អត្រាបែងចែកចំណូល | | | | |
|---|---|---|---|---|---|---|
| | | បង់ចូលថវិកា រ.កសខ | រង្វាន់ រ.កសខ | រង្វាន់ រ.ឃស | រង្វាន់ ម.សហវ | រង្វាន់ អ.រប នៃ ក.មផ |
| ខ- | ចំណូលពីការផ្តល់សេវារដ្ឋបាលលើការងាររដ្ឋបាល ដែលប្រមូលបានដោយ | | | | | |
| ១- | រដ្ឋបាលខណ្ឌ | ២៩% | ៦៤% | ៥% | ១% | ១% |
| ២- | រដ្ឋបាលក្រុង | ១៩% | ៧៤% | ៥% | ១% | ១% |
| ៣- | រដ្ឋបាលស្រុក | ៩% | ៨៤% | ៥% | ១% | ១% |
| គ- | ចំណូលពីការផ្តល់សេវារដ្ឋបាលផ្សេងៗទៀត ក្រៅពីចំណុច "ក" និងចំណុច "ខ" ខាងលើ ដែលប្រមូលបានដោយ | | | | | |
| ១- | រដ្ឋបាលខណ្ឌ | ៤៩% | ៤៤% | ៥% | ១% | ១% |
| ២- | រដ្ឋបាលក្រុង | ៣៩% | ៥៤% | ៥% | ១% | ១% |
| ៣- | រដ្ឋបាលស្រុក | ២៩% | ៦៤% | ៥% | ១% | ១% |

**កំណត់សម្គាល់៖**

- ពាក្យ "រ.កសខ" មានន័យថា "រដ្ឋបាលក្រុង ស្រុក ខណ្ឌ"
- ពាក្យ "រ.ឃស" មានន័យថា "រដ្ឋបាលឃុំ សង្កាត់"
- ពាក្យ "ម.សហវ" មានន័យថា "មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត"
- ពាក្យ "អ.រប នៃ ក.មផ" មានន័យថា "អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ" ។

**ប្រការ២ .-**

អនុញ្ញាតឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ បុរេប្រទានប្រាក់រង្វាន់សរុបពីចំណូលប្រមូលបាន និងបើកផ្តល់ចំណែកប្រាក់រង្វាន់ជូនដល់អង្គភាពគោលដៅនីមួយៗ ដែលបានកំណត់ក្នុងប្រការ១ នៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ៣ .-**

ជារៀងរាល់ខែ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការទូទាត់ប្រាក់រង្វាន់ដែលបានបុរេប្រទានប្រចាំខែ ដោយអនុវត្តតាមនីតិវិធីដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៤ .-**

ប្រាក់រង្វាន់របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដូចមានចែងក្នុងប្រការ១ នៃប្រកាសអន្តរក្រសួងនេះ ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់សម្រាប់ការចំណាយឧបត្ថម្ភជូនបុគ្គលិក មន្ត្រីរាជការ ដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត និងពង្រឹងយន្តការប្រមូលចំណូល។

ការបើកផ្តល់ប្រាក់រង្វាន់ជូនបុគ្គលិកនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុលោមតាមការសម្រេចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌសាមី ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ការឧបត្ថម្ភប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ការឧបត្ថម្ភប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

**ប្រការ៥ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ ._**

អគ្គលេខាធិការ អគ្គស្នងការ អគ្គនាយក អគ្គាធិការ និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងក្រុមប្រឹក្សា និងអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ... ខែ ... ឆ្នាំ ... ស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អង្គភាពប្រឆាំងអំពើពុករលួយ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៣៧៥.....សហវ.ប្រក

ក្រសួងសាធារណការ និងដឹកជញ្ជូន

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការកែសម្រួលគណៈកម្មាធិការ សម្រាប់គ្រប់គ្រងកិច្ចព្រមព្រៀងសម្បទានគម្រោង ផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងសាធារណការ និងដឹកជញ្ជូន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២១/០១៨ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញអនុក្រឹត្យលេខ ២២០ អនក្រ.បក ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដំឡើងនាយកដ្ឋានសំណង់ប្រព័ន្ធចម្រោះទឹកកខ្វក់ទៅជាអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១ ស្តីពីការប្រែក្លាយ និងដំឡើងវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេសសាធារណការ និងដឹកជញ្ជូន ទៅជាវិទ្យាស្ថានតេជោសែនសាធារណការ និងដឹកជញ្ជូន របស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការដំឡើងនាយកដ្ឋានព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ ទៅជាអគ្គនាយកដ្ឋានបច្ចេកវិទ្យា និងទំនាក់ទំនងសាធារណៈ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញប្រកាសអន្តរក្រសួងលេខ ៧៥៣ សហវ.ប្រក.អវជ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលគណៈកម្មាធិការសម្រាប់គ្រប់គ្រងកិច្ចព្រមព្រៀងសម្បទានគម្រោងផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

**ប្រការ១.—**

ត្រូវបានកែសម្រួលគណៈកម្មាធិការសម្រាប់គ្រប់គ្រងកិច្ចព្រមព្រៀងសម្បទានគម្រោងផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ ហៅកាត់ថា "**គ.ក.ផ.**" រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "កសហវ " និងក្រសួងសាធារណការ និងដឹកជញ្ជូន "កសដ " ដែលមានសមាសភាព ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **មាស សុខសេនសាន** | រដ្ឋលេខាធិការ កសហវ | សហប្រធាន |
| ២. | ឯកឧត្តម **សួន ហេង** | រដ្ឋលេខាធិការ កសដ | សហប្រធាន |
| ៣. | ឯកឧត្តម **ស៊ឹម វីរៈ** | អនុរដ្ឋលេខាធិការ កសហវ | អនុប្រធាន |
| ៤. | ឯកឧត្តម **ស៊ឹង សុគង់** | អនុរដ្ឋលេខាធិការ កសដ | អនុប្រធានប្រចាំការ |
| ៥. | ឯកឧត្តម **នឹម សុធា** | អនុរដ្ឋលេខាធិការ កសដ | អនុប្រធាន |
| ៦. | ឯកឧត្តម **ឱម ម៉ាក់ធារិទ្ធ** | អគ្គនាយក នៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន កសហវ | អនុប្រធាន |
| ៧ | ឯកឧត្តម **នេត មុន្នី** | រដ្ឋលេខាធិការ កសហវ | សមាជិក |
| ៨. | ឯកឧត្តម **ហេង រត្នពិសិដ្ឋ** | អគ្គនាយក នៃអគ្គនាយកដ្ឋានសាធារណការ កសដ | សមាជិក |
| ៩. | ឯកឧត្តម **ឡុន សំបូរ** | អគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ កសហវ | សមាជិក |
| ១០. | ឯកឧត្តម **ហ៊ាង ឌុត្តា** | អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស កសដ | សមាជិក |
| ១១. | ឯកឧត្តម **កែន រដ្ឋា** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ កសដ | សមាជិក |
| ១២. | ឯកឧត្តម **ឈួន វ៉ាន់** | អគ្គនាយក នៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក កសដ | សមាជិក |

| | | |
|---|---|---|
| ១៣. ឯកឧត្តម **ទេស តារាវ័ត្ត** | អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យា និងទំនាក់ទំនងសាធារណៈ កសដ | សមាជិក |
| ១៤. លោក **ឈុំ សុខ** | ប្រធាននាយកដ្ឋានផ្លូវល្បឿនលឿន ស្ពានធំៗ និងវិនិយោគ កសដ | សមាជិក |

**ប្រការ២.–**

**គ.ក.ផ.** មានភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំ ត្រួតពិនិត្យ ការអនុវត្តរួមនៃគម្រោងផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ សំដៅធានាអនុលោមភាព និងការបំពេញកាតព្វកិច្ចរបស់គូភាគីក្រោមកិច្ចព្រមព្រៀងសម្បទាន
- សម្រេច និងអនុម័តលើការងារពាក់ព័ន្ធនឹងការគ្រប់គ្រងកិច្ចព្រមព្រៀងសម្បទានគម្រោងផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ លើកលែងតែកិច្ចការទាក់ទងនឹងកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈ ដែលស្ថិតក្រោមដែនសមត្ថកិច្ច និងទាមទារការសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងករណីមានវេទយិតភាព ត្រូវស្នើសុំការសម្រេចពីរាជរដ្ឋាភិបាល
- ជំរុញ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតរបស់រាជរដ្ឋាភិបាល និងក្រុមហ៊ុនសម្បទានិក ដើម្បីដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធការអនុវត្តកិច្ចព្រមព្រៀងសម្បទាន ព្រមទាំងផ្តល់អនុសាសន៍ណែនាំគ្រប់ភាគីពាក់ព័ន្ធ ដើម្បីបំពេញកាតព្វកិច្ច ដូចមានចែងក្នុងកិច្ចព្រមព្រៀងសម្បទាន
- គ្រប់គ្រងសំណើកែសម្រួលក្នុងកិច្ចព្រមព្រៀងសម្បទានគម្រោងផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ, ការបែងចែកហានិភ័យ, ការដោះស្រាយសំណង/វិវាទ, និងដំណោះស្រាយផ្សេងៗទៀត រួមទាំងការរំលាយកិច្ចសន្យា។ ក្នុងករណីសំណើកែសម្រួលទាំងនោះមានផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ ត្រូវលើកសំណើទាំងនោះជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសម្រេច
- ពិនិត្យ និងអនុម័តលើរបាយការណ៍វឌ្ឍនភាព របាយការណ៍ប្រចាំត្រីមាស និងរបាយការណ៍ពាក់ព័ន្ធផ្សេងៗទៀត
- បំពេញមុខងារផ្សេងទៀតតាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

**ប្រការ៣.–**

**គ.ក.ផ.** មានអង្គភាពគ្រប់គ្រងគម្រោង ជាលេខាធិការដ្ឋាន។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពគ្រប់គ្រងគម្រោង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

**ប្រការ៤.–**

អនុប្រធាន និងសមាជិកនៃ **គ.ក.ផ.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់សហប្រធាន។ ក្នុងករណីចាំបាច់, **គ.ក.ផ.** អាចអញ្ជើញមន្ត្រីជំនាញពាក់ព័ន្ធផ្សេងទៀតពី កសហវ និង កសដ, ក្រសួង ស្ថាប័នពាក់ព័ន្ធ, ទីប្រឹក្សា និងជំនាញការផ្សេងៗ ឱ្យចូលរួមប្រជុំ តាមតម្រូវការចាំបាច់។

ក្នុងករណីសហប្រធានអវត្តមាន អនុប្រធានមានសិទ្ធិពេញលេញ ដើម្បីដឹកនាំកិច្ចប្រជុំតាមការប្រគល់សិទ្ធិរបស់សហប្រធាន។

**គ.ក.ផ.** មានសិទ្ធិបង្កើតអនុគណៈកម្មការចំពោះកិច្ច ក្នុងករណីចាំបាច់ដើម្បីពិនិត្យ និងផ្តល់អនុសាសន៍ជាដំណោះស្រាយចំពោះបញ្ហាជាក់លាក់ណាមួយ។

**ប្រការ៥.—**

លេខាធិការដ្ឋានប្រើប្រាស់ថវិការដ្ឋ ឬប្រភពហិរញ្ញប្បទានស្របច្បាប់ផ្សេងៗទៀត សម្រាប់ទ្រទ្រង់កិច្ចដំណើរការរបស់ខ្លួន និង **គ.ភ.ផ.** តាមការចាំបាច់ ដោយលើកសំណើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសម្រេចតាមនីតិវិធីជាធរមាន។

**ប្រការ៦.—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧.—**

អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ២ កើត ខែ ជេស្ឋ ឆ្នាំ មមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ឧសភា គ.ស.២០២៦

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងសាធារណការ និងដឹកជញ្ជូន**

**ប៉េង_ពោធិ៍នា**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៣៤......សហវ.ស.ក.រ.ស.ក.

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមលទ្ធកម្មរបស់
# អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៩៦ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៥ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៣២ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម
- បានឃើញអនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការដាក់ឱ្យអនុវត្តអង្គភាពថវិកា

- បានឃើញប្រកាសលេខ ៨៥៦ សហវ.ប្រក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្ត គោលការណ៍ណែនាំស្តីពីការរៀបចំ និងចាប់ផ្តើមអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ២៣៧ សហវ.ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់ គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្ត គោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១២៨២ សហវ.ប្រក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា
- បានឃើញប្រកាសលេខ ១៨៦ សហវ.ប្រក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ ស្តីពីការប្រគល់សិទ្ធិ ជាអាណាប័កផ្ទេរសិទ្ធិជូនប្រធានអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៧៦៦ សហវ.ប្រក ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការបង្កើតនិង តែងតាំងក្រុមលទ្ធកម្មរបស់អង្គភាពថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៩៨០ សហវ.ប្រក.អលសា ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅនៃក្រុមលទ្ធកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១** .-

ត្រូវបានបង្កើតក្រុមលទ្ធកម្មរបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **ម៉ាន់ គិរមៀ** | អគ្គនាយក | ប្រធាន |
| ២. ឯកឧត្តម **សេខ ស្រេខ** | អគ្គនាយករង | អនុប្រធាន |
| ៣. លោក **ហ៊ីង ពៅ** | ប្រធាននាយកដ្ឋាន | សមាជិក |
| ៤. លោក **ឌី សោភ័ណា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៥. លោក **ជុំ តក្កា** | ប្រធានការិយាល័យ | សមាជិក។ |

**ប្រការ២** .-

ក្រុមលទ្ធកម្មនេះមានភារកិច្ចដូចតទៅ៖

- រៀបចំ ពិនិត្យ និងសម្រេចលើសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ និង/ឬផែនការលទ្ធកម្មកែតម្រូវ
- អនុវត្តកិច្ចលទ្ធកម្មស្របតាមផែនការលទ្ធកម្មដែលទទួលបានការអនុម័តរួច
- កំណត់បុរេលក្ខណសម្បត្តិ ចំពោះកិច្ចលទ្ធកម្មដែលមានលក្ខណៈបច្ចេកទេសស្មុគស្មាញ
- រៀបចំ ពិនិត្យ និងសម្រេចលើឯកសារដេញថ្លៃ
- រៀបចំ ផ្សព្វផ្សាយ និងចម្លងជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនូវសេចក្តីជូនដំណឹងអំពីការដេញថ្លៃ
- លក់ឬផ្តល់ឯកសារដេញថ្លៃជូនអ្នកមានបំណងចូលរួមដេញថ្លៃ
- ទទួលសំណុំឯកសារស្នើដេញថ្លៃ និងបកស្រាយបំភ្លឺចំពោះអ្នកដេញថ្លៃ ក្នុងករណីមានសំណួរ ពាក់ព័ន្ធនឹងការដេញថ្លៃ
- រៀបចំនិងគ្រប់គ្រងសំណុំឯកសារស្នើដេញថ្លៃ រួមទាំងឯកសារពាក់ព័ន្ធដែលបានទទួលឱ្យបាន ត្រឹមត្រូវនិងមានសុវត្ថិភាព មុនពេលបើកសំណុំឯកសារស្នើដេញថ្លៃ

- ប្រជុំបើកសំណុំឯកសារស្នើដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃ ឬចរចាថ្លៃ
- រៀបចំរបាយការណ៍ឬកំណត់ហេតុស្តីពីការបើកសំណុំឯកសារស្នើដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃ ឬចរចាថ្លៃ
- ប្រជុំវាយតម្លៃសំណុំឯកសារស្នើដេញថ្លៃ
- ត្រួតពិនិត្យនិងវាយតម្លៃលក្ខណសម្បត្តិតាមក្រោយរបស់អ្នកដេញថ្លៃនាំមុខ
- រៀបចំនិងធ្វើលិខិតជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យាដល់អ្នកដេញថ្លៃឈ្នះ និង ចម្លងជូនគ្រប់អ្នកដេញថ្លៃចាញ់
- ឆ្លើយតបចំពោះសំណួរពាក់ព័ន្ធនឹងលទ្ធផលនៃការដេញថ្លៃ
- បញ្ជូនឯកសារដេញថ្លៃ សំណុំឯកសារស្នើដេញថ្លៃ និងការស្នើសុំជ្រើសរើសនិងប្រគល់កិច្ចសន្យាទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងសម្រេច ចំពោះគម្រោងលទ្ធកម្មដែលត្រូវពិនិត្យនិងសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រៀបចំសេចក្តីព្រាងកិច្ចសន្យា និងចុះកិច្ចសន្យាជាភាគីនៃកិច្ចសន្យា ដោយអនុលោមតាមបទដ្ឋាននិងគំរូកិច្ចសន្យាដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តកិច្ចសន្យា
- អញ្ជើញតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចូលរួមសង្កេតការណ៍ នៅដំណាក់កាលបើកសំណុំឯកសារស្នើដេញថ្លៃ ប្រជុំចរចាថ្លៃ និងការប្រគល់ ទទួល ចំពោះគម្រោងលទ្ធកម្មដែលត្រូវពិនិត្យនិងសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពិនិត្យនិងដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មតាមសមត្ថកិច្ចរបស់ខ្លួន
- ផ្សព្វផ្សាយផែនការលទ្ធកម្ម លទ្ធផលនៃការដេញថ្លៃ និងលទ្ធផលនៃការដោះស្រាយបណ្តឹងតវ៉ា
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំត្រីមាស ឆមាស និងឆ្នាំ។

**ប្រការ៣** .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤** .-

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ គ្រប់ប្រធានអង្គភាព នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាមីខ្លួន ដូចមានរាយនាមក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១១កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ០៤៤.....................

ថ្ងៃ.......... ខែ.......... ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.......... ខែ.......... ឆ្នាំ២០២៦

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ០០៥/១៧ ត.ត.ស.ព ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រផលិតគ្រឿងបន្លាស់កង់ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងលិខិតលេខ១៧៥/២៥ ត.ត.ស.ព ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការប្តូរអភិបាល របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៥ របស់ក្រុមហ៊ុន ធេនថេក ខមភើហ្សាយ (ខេមបូឌា) ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ធេនថេក ខមភើហ្សាយ (ខេមបូឌា) ឯ.ក **(TENTECH COMPOSITE (CAMBODIA) CO., LTD.)** តំណាងដោយលោក **CHEN, CHIN-SUNG** សញ្ជាតិចិន(តៃវ៉ាន់) កាន់លិខិតឆ្លងដែនលេខ **360044867** ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ បង្កើតរោងចក្រផលិតគ្រឿងបន្លាស់ទោចក្រយាន (កង់) ដែលមានទីតាំងស្ថិតនៅតំបន់សេដ្ឋកិច្ចពិសេសស តាយសេងបាវិត (ភូមិតាបីប សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង)។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
| --- | --- |
| គ្រឿងបន្លាស់ទោចក្រយាន (កង់) | ៣០៩២ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រផលិតគ្រឿងបន្លាស់ទោចក្រយាន (កង់) ជេនថេក ខមភើហ្សាយ (ខេមបូឌា) ឯ.ក** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបាន ឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការ របស់រោងចក្រស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ៥៦១ ឧវបន.កឧ.ប្រក ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២ និងលិខិតលេខ១១៤ ឧវបន.កឧ.លស ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២៦ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តស្វាយរៀង និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ចម្លងជូន៖**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងបរិស្ថាន
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -រាជកិច្ច
- -ខុទ្ទកាល័យរដ្ឋមន្ត្រី
- -សាលាខេត្តស្វាយរៀង
- -មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តស្វាយរៀង
- -រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសស តាយសេងបាវិត "ដើម្បីជូនជ្រាប"
- -ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

បណ្ឌិត ទឹម ស៊ីនី

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងបណ្ណសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី